STREAM

ឆ្នាំទី១ លេខ៤ ខែ តុលា-ធ្នូ ២០០២

**Support to Regional Aquatic Resources Management**
**គំរោងជួយគ្រប់គ្រងធនធានវារីជាតក្នុងតំបន់**

# ទស្សនាវដ្ដី STREAM

## ការទំនាក់ទំនង និង ការរៀនសូត្រពីជីវភាពរស់នៅរបស់អ្នកនេសាទ និង កសិករ

គំរោងត្រូវបានការជួយឧបត្ថម្ភដោយ AusAID, DFID, FAO, NACA និង VSO

# មាតិកា

| អត្ថបទ | ទំព័រ |
|---|---|
| គំរោងសាកល្បងការគ្រប់គ្រងធនធានធម្មជាតិតាមបែបសហគមន៍នៅតំបន់ការពារ(សមុទ្រ) Hon Mun | ១ |
| *Nguyen Thi Hai និង Bernard Adrien* | |
| បទពិសោធន៍ការស្រាវជ្រាវដោយមានការចូលរួម ក្នុងបឹងទឹកប្រៃ Tam Giang, Thua Thien-Hue | ៤ |
| *Ton That Chat* | |
| បទពិសោធន៍ និង ផលប្រយោជន៍នៃការវិភាគការចិញ្ចឹមជីវិត | ៧ |
| *Michael Reynaldo, Orlando Arciaga, Fernando Gervacio និង Catherine Demesa* | |
| បទពិសោធន៍ការអនុវត្តន៍ PRA ក្នុងការវិភាគការចិញ្ចឹមជីវិត | ១០ |
| *Nguyen Thi Thuy* | |
| បទពិសោធន៍ពីការវិភាគការចិញ្ចឹមជីវិត និង PRA នៅតំបន់ផ្កាថ្មបំរុងទុក Trao | ១២ |
| *Nguyen Viet Vinh* | |
| ការប្រើប្រាស់លទ្ធផលពីការវាយតំលៃភាពក្រីក្រដោយមានការចូលរួមនៅខេត្ត Tra Vinh | ១៥ |
| *Le Quang Binh* | |
| ពត៌មានពីទស្សនាវដ្តីរបស់ **STREAM** | ១៨ |
| ពត៌មានពី **STREAM** | ២០ |

**<u>កំណត់ចំណាំៈ</u>**

ពីមួយថ្ងៃទៅមួយថ្ងៃ ទស្សនាវដ្ដី STREAM បានចុះផ្សាយអត្ថបទពិសេសៗ ដែលផ្ដោតលើព្រឹត្តិការណ៍សំខាន់។ នៅខែ វិច្ឆិកា ២០០២ ការិយាល័យនិន្នាការភាពវារីវប្បកម្មដើម្បីលើកកំពស់ភាពក្រីក្រ (SAPA) នៃក្រសួងជលផលវៀតណាម និង គំរោង STREAM បានរៀបចំសិក្ខាសាលារៀនសូត្រស្ដីពី "ការវិភាគការចិញ្ចឹមជីវិត" (សូមមើលរបាយការណ៍នៅបណ្ណាល័យលើ Website: www.streaminitiative.org)។ ឥឡូវនេះយើងមានសេចក្ដីរីករាយចុះផ្សាយអត្ថបទចំនួន ៦ ដែលបានមកពីការធ្វើបទបង្ហាញពីសិក្ខាសាលានៅខេត្ត Long An។ អត្ថបទដែលបានមកពីការធ្វើបទបង្ហាញផ្សេងទៀតនឹងចុះផ្សាយនៅលេខក្រោយៗទៀត។

គោលសំខាន់ៗនៃលេខទី៤ នេះគឺការវិភាគការចិញ្ចឹមជីវិតដោយមានការចូលរួម ដោយអត្ថបទទាំងនេះផ្ដល់ពត៌មានលំអិតពីដំណើរការ ការអនុវត្តន៍ និង បទពិសោធន៍ពីប្រទេសវៀតណាម និង ហ្វីលីពីន។ អ្នកនិពន្ធ និង ទីកន្លែងរបស់ពួកគេធ្វើការនៅវៀតណាមគឺ (លើកលែងមួយករណី): Nguyen Thi Hai Yen និង Bernard Adrien (Hon Mun); Ton That Chat (Tam Giang Lagoon); Micheal Reynaldo, Orlando Arciaga, Fernando Gervacio និង Catherine Demesa (Bolinao, Philippines), Nguyen Thi Thuy (Hanoi), Nguyen Viet Vinh (Trao Reef); និង Le Quang Binh (Tra Vinh).

យើងសូមថ្លែងអំណរគុណដល់ការបោះពុម្ពលេខមុននៃអត្ថបទទាំង៣នេះ: រៀនពីការគ្រប់គ្រងធនធានតាមបែបសហគមន៍ ១ (៣ និង ៤) (កក្កដា-ធ្នូ ២០០២) ការបោះពុម្ពនៃ LeaRN (រៀនពីការគ្រប់គ្រងធនធានតាមបែបសហគមន៍ និង បណ្ដាញស្រាវជ្រាវ) មជ្ឈមណ្ឌលធនធានសំរាប់ការគ្រប់គ្រងធនធានតាមបែបសហគមន៍ ក្នុងប្រទេសហ្វីលីពីន www.cbcrmlearning.org ។ នេះគឺជា ផ្នែកមួយនៃគំរោង Hon Mun, Bolinao និង Trao Reef។

ការបកប្រែទស្សនាវដ្ដី STREAM ត្រូវបានពង្រីក និង ចាប់ផ្ដើមមានឥទ្ធិពល។ ការបកប្រែទស្សនាវដ្ដី STREAM ជាភាសាអ៊ីឡុងហ្គូ (ភាសាជនជាតិហ្វីលីពីន) នាពេលថ្មីៗនេះឥឡូវមាននៅលើបណ្ណាល័យ Website។ Jesper Clausen ជាអ្នកសរសេរអត្ថបទ " បង្កាខ្លឹងនៅភាគកណ្ដាលប៉ែកខាងជើងប្រទេសវៀតណាម "ក្នុងទស្សនាវដ្ដី STREAM លេខ ១ ឆ្នាំទី១ បានប្រាប់យើងថា មិត្តភ័ក្ដិរបស់គាត់ដែលចិញ្ចឹមបង្កានៅ Nghe An ប្រទេសវៀតណាម បានផ្ញើអ៊ីមែលនិយាយ ពីអត្ថបទនេះ។ គាត់បានសរសេរថា គាត់មិនដែលបានទទួលពត៌មាន និង ការបកប្រែជាភាសាវៀតណាមនៃទស្សនាវដ្ដី STREAM ដល់ខេត្តរបស់គាត់ទេ។

សូមលោកអ្នកអានដោយក្ដីរីករាយ

លោក Graham Haylor នាយកគំរោង STREAM

លោក William Savage បណ្ណាធិការទស្សនាវដ្ដី STREAM

## គំរោងសាកល្បងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍

## នៅតំបន់សមុទ្រដែលត្រូវការពារ Hon Mun

*Nguyen Thi Hai និង Bernard Adrien*

### ចរិតលក្ខណៈនៃប្រជាជននៅតំបន់សមុទ្រដែលត្រូវការពារ

ភូមិ៦ នៃតំបន់ការពារសមុទ្រមានប្រជាជនជាង ៥ ពាន់នាក់ ប្រហែល ១ ពាន់គ្រួសារ ដែលមានសមាមាត្រស្មើគ្នារវាង បុរស និង ស្ត្រី។ របាយប្រជាជនមិនមានភាពស្មើគ្នានៅតាមភូមិនិមួយៗ (ភូមិខ្លះមាន ៣២គ្រួសារ ឯភូមិខ្លះទៀតមាន រហូតដល់ ៥00 គ្រួសារ)។ មុខរបរសំខាន់គឺនេសាទ ក្នុងនោះ ៨0%នៃមេគ្រួសារគឺជាអ្នកនេសាទ។ ភាគច្រើនគ្មានមុខរបរ ផ្សេងក្រៅពីនេសាទ ដូច្នេះការចិញ្ចឹមជីវិតងាយទទួលរងគ្រោះ។ វារីវប្បកម្មបានអភិវឌ្ឍន៏យ៉ាងលឿននៅក្នុងរយៈ ពេល ៣ ឆ្នាំចុងក្រោយនេះ ហើយនាពេលបច្ចុប្បន្ន ៣0%នៃគ្រួសារបានធ្វើវារីវប្បកម្ម។ ភាគច្រើននៃ ប្រជាជននៅតំបន់សមុទ្រដែលត្រូវការពារបានគិតថា ពួកគេជាអ្នក "មធ្យម"។ កំរិតនៃភាពក្រីក្រជាក់ស្តែង មានភាពខុសគ្នា ពីភូមិមួយទៅភូមិមួយ ពីតិចជាង ១0% ទៅ ជាង ៥0%នៃប្រជាជននៅក្នុងភូមិ។



ជាទូទៅ កំរិតវប្បធម៌នៃមនុស្សពេញវ័យគឺមានកំរិតទាប ហើយក្នុងនោះស្ត្រីមានការចេះដឹងច្រើនជាងបុរស។ ជាទូទៅសមាមាត្រនៃកុមារមិនទៅសាលារៀនគឺមានអត្រាខ្ពស់។ ស្ថានភាពជីវជាតិបានឆ្លុះបញ្ចាំងពីចរិតលក្ខណៈនៃភូមិនៅលើកោះ ឧទា. ពឹងផ្អែកខ្លាំងលើការនេសាទ និង កំហិតការប្រើប្រាស់ផលិតផលកសិកម្ម។

ស្ទើរតែពាក់កណ្តាលនៃផ្ទះគឺជាផ្ទះសាមញ្ញ និង ២ ឬ ៣ ជាផ្ទះធុនមធ្យម។ ចំនួនអ្នកមានម៉ាស៊ីនភ្លើងបានកើនឡើង និងជាងពាក់កណ្តាលនៃអ្នកភូមិមានទូរទស្សន៍។ នៅរដូវប្រាំង ទឹកសាបត្រូវដឹកមកពីដីគោក ហើយអ្នកភូមិត្រូវទិញទឹកនេះ។

### សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ចំណូលជាមធ្យមក្នុងមួយនាក់ក្នុងឆ្នាំ ២00១ គឺ ៥,៧៤ លានដុង (ឧទា. ៤៧៨.000 ដុង ក្នុងមួយខែ) ហើយការចំណាយជាមធ្យមក្នុងមួយនាក់គឺ ៣,៦៨ លានដុង (៣0៦.000 ដុង ក្នុងមួយខែ)ដែលក្នុងនោះ ការចំណាយទៅលើចំណីអាហារគឺពាក់កណ្តាលនៃការចំណាយសំរាប់ការរស់នៅ។ ជាមធ្យមគេអាចសន្សំបាន ៣៦%នៃប្រាក់ចំណូល (១៦% សំរាប់អ្នកក្រ និង ៤0% សំរាប់អ្នកមាន)។

អ្នកនេសាទដែលមានជីវភាព "មធ្យម" និង "មាន"ស្ទើរតែមានទូកគ្រប់ៗគ្នា ចំណែកឯអ្នកក្រធ្វើជាអ្នកស៊ីឈ្នួលគេ។ ជាទូទៅពួកគេចេញនេសាទនៅពេលយប់ ដោយប្រើអួនធំៗប្រភេទផ្សេងៗគ្នា រួមផ្សំនឹងភ្លើងហ្វា មុជទឹក (ជួនកាលប្រើថ្នាំ) និង

ស្ងួចមឹក។ ប្រាក់ចំណេញសំរាប់អ្នកមានទូកគឺពី ៤៣.០០០- ៣៤០.០០០ ដុង ក្នុងមួយថ្ងៃ និង ពី ១៤.០០០- ៦៦.០០០ ដុង សំរាប់ទូកដែលជួលកម្មករ។

ជាមធ្យមគ្រួសារដែលចិញ្ចឹមបង្កងសមុទ្រមានបែរពីរ ដែលអាចរកប្រាក់ចំណេញ ១៧ លានដុង ក្នុងរយៈពេលចិញ្ចឹម ១,៥ ឆ្នាំ។ កសិកម្ម (ឧទា. ដំណាំផ្លែឈើ និង ដំឡូង) ការចិញ្ចឹមសត្វ (ឧទា. ជ្រូក មាន់ ទា) និង លក់រាយគឺមានសារៈសំខាន់នៅក្នុងភូមិខ្លះ។ កម្មវិធីឥណទានរបស់រដ្ឋាភិបាលជាច្រើន បានផ្តល់ឥណទានដល់ប្រជាជនតាមរយៈក្រុមឥណទាន។ ប្រហែល ៦០% នៃគ្រួសារបានទទួលឥណទានជាមធ្យម ៤.៧ លានដុង ជាពិសេសគឺផ្តល់ឱ្យដល់ការចិញ្ចឹមត្រី។

## ទស្សនៈរបស់អ្នកភូមិ

*បញ្ហាបរិស្ថាន*

អ្នកភូមិទាំងអស់បានលើកឡើងនូវបញ្ហាសំខាន់៣: ធនធានត្រីបានថយចុះយ៉ាងខ្លាំងក្នុងរយៈពេល ១០-១៥ ឆ្នាំចុងក្រោយនេះ តំបន់ផ្កាថ្មបានខូចខាតយ៉ាងខ្លាំង និង មានការបំពុល។



ប្រជាជនពិភាក្សាគ្នា និង ធ្វើការផ្តល់យោបល់ពីអនាគតរបស់ពួកគេ

អ្នកភូមិទាំងអស់បានដឹងពីការថយចុះធនធានត្រី ដោយសារតែមានការនេសាទហួសហេតុ (ដោយសារការកើនឡើងនូវចំនួន និង ប្រសិទ្ធិភាពនៃទូកនេសាទ និង ឧបករណ៍នេសាទ និង ការកើនឡើងចំនួនប្រជាជន) រួមផ្សំនឹងការនេសាទ បំផ្លិចបំផ្លាញ និង ខុសច្បាប់ (ឧទា. អួនអូស, អួនដោយប្រើភ្លើងហ្វា, ប្រើថ្នាំពុល និង គ្រាប់បែក)។ ដើម្បីដោះស្រាយផលវិបាកនេះ អ្នកភូមិទាំងអស់បានស្នើរឡើងនូវសកម្មភាពជាច្រើនដែលរួមមាន: ទុកកន្លែងបំរុងសំរាប់អ្នកភូមិ ពង្រឹងច្បាប់ជាតិដែលមានដើម្បីបង្រ្កាបបទល្មើសនេសាទ និង បង្កើតច្បាប់ថ្មីទាក់ទងនឹងការបង្កើតជាតំបន់ លើកកំពស់ប្រសិទ្ធិភាពនៃស្ថាប័នពាក់ពន្ធ័ និង ការចូលរួមរបស់អ្នកភូមិក្នុងសកម្មភាពពង្រឹងច្បាប់ សកម្មភាពអប់រំដល់អ្នកភូមិ ជាពិសេសលើបរិស្ថាន សកម្មភាពទាក់ទងនឹងការរកប្រាក់ចំណូល និង ឥណទាន។

អ្នកភូមិបានរកឃើញនូវមូលហេតុសំខាន់នៃការបំផ្លាញផ្កាថ្មដោយសារការបោះយុថ្កា (អ្នកទេសចរ និង ទូកនេសាទ) ការប្រើអួននៅតំបន់ផ្កាថ្ម និង ការប្រើថ្នាំពុល និង គ្រាប់បែក។ សំណើរសកម្មភាពរួមមាន: បង្កើតពោងសំរាប់ចងទូកកុំឱ្យរសាត់ ពង្រឹងឱ្យប្រើប្រាស់សមស្រប ដោយមានការចូលរួមពីអ្នកភូមិ។

វាមិនមានការពិបាកសំរាប់អ្នកភូមិរកឱ្យឃើញនូវប្រភពនៃការបំពុល ពីសំរាម លាមកមនុស្ស ប្រេងកំពប់ និង កាកសំណល់ពីវារីវប្បកម្ម។ សំណើរសកម្មភាពរួមមាន: បង្កើតប្រពន្ធ័គ្រប់គ្រងកាកសំណល់ លើកកំពស់ការយល់ដឹង និង អប់រំ លើកទឹកចិត្តអ្នកភូមិឱ្យបង្កើតបង្គន់ឯកជន ដោះស្រាយបញ្ហាប្រេងដែលប្រើប្រាស់រួច ហើយ កំណត់ និង អនុវត្ត ផែនការអភិវឌ្ឍន៍វារីវប្បកម្ម។

**បញ្ហាសង្គម**

នៅពេលធ្វើការវាយតំលៃដោយមានការចូលរួម（PRA）អ្នកភូមិបានរកឃើញនូវសេវាសង្គម និង ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដែល ត្រូវកែលំអរ（សំខាន់គឺអគ្គិសនី និង ទឹកសាប）និង បញ្ហាស្ត្រីគ្មានការងារធ្វើ។ លទ្ធផលនៃ(PRA) បានបង្ហាញថាស្ត្រីនៅក្នុភូមិខ្លះ មានពេលប្រហែល ៧0%ដើម្បីធ្វើការងាររកលុយ។

**ការចង់បានរបស់សហគមន៏ទាក់ទងនឹងសេដ្ឋកិច្ច-សង្គម**

ការចង់បានរបស់សហគមន៏បានឆ្លុះបញ្ចាំងពីសកម្មភាពសេដ្ឋកិច្ចដែលប្រជាជនគិតថា អាចធានា និង ចំណេញបានច្រើនគឺ（ការចិញ្ចឹមបង្កងសមុទ្រ）ក៏ដូចជាការងារដែលសំរាប់ឱ្យស្ត្រីធ្វើ។ វារីវប្បកម្មត្រូវបានគេគិតថាជាសកម្មភាពជាអាទិភាពក្នុងការអភិវឌ្ឍន៏ សំរាប់បុរស និង ស្ត្រី។ ការនេសាទ និង ការចិញ្ចឹមសត្វក៏ត្រូវបានគេគិតថាមានអាទិភាពដែរ។

*Nguyen Thi Hai និង Bernard Adrien*គឺជាអ្នកជំនាញការខាងការគ្រប់គ្រងធនធានធម្មជាតិតាមបែបសហគមន៏ធ្វើការជាមួយ IUCN (World Conservation Union) នៃគំរោងតំបន់សមុទ្រដែលត្រូវការពារ Hon Mun នៅក្នុងខេត្ត Nga Trang នៃប្រទេសវៀតណាម ។យើងអាចទាក់ទងតាមរយៈ < community@honmunmpa.org.vn>

## បទពិសោធន៍ការស្រាវជ្រាវដោយមានការចូលរួម ក្នុងបឹងទឹកប្រៃ Tam Giang, Thua Thien-Hue

*Ton That Chat*

### បឹងទឹកប្រៃ

បឹងទឹកប្រៃ Tam Giang នៅក្នុងខេត្ត Thua Hue នៃប្រទេសវៀតណាម មានផ្ទៃក្រលា ២២.០០០ ហ.ត ដែលមានបណ្តោយវែងជាង ៦០ គ.ម ។ ចុងខាងកើតនៃផ្នែកខាងកើតជាប់នឹងសមុទ្រតាមរយៈដៃព្រែកពីរ- THuan និង Tu Hien ចំណែកឯផ្នែកខាងលិចគឺជាវាលស្រែ និង ដៃទន្លេ ។ មួយផ្នែកនៃបឹងគឺបិទជិត ដែលធ្វើឱ្យ Tam Giang មានប្រពន្ធ័អេកូឡូស៊ីទឹកភ្លាវដោយមានធនធានចំរុះ ដោយជួយផ្គត់ផ្គង់ដល់សហគមន៍នេសាទដ៏ធំដែលរស់នៅលើទូក និង ភូមិនៅជុំវិញបឹងទឹកប្រៃ ។




តំបន់បឹងដែលមានជំរៅរាក់ដែលទទួលបានទាំងទឹកសាប និង ទឹកប្រៃ ដែលធ្វើឱ្យមានការប្រែប្រួលជាទៀងទាត់ តាមរដូវនូវកំហាប់អំបិល ។ បាតខាងក្រោមគឺមានផ្ទៃរាបស្មើរដែលមានជំរៅជាមធ្យម ២ ម៉ែត្រ ស្មើរគ្រប់ទីកន្លែង លើកលែងតែប្រឡាយខ្លះដែលអាចមានជំរៅរហូតដល់ ៣-៤ ម៉ែត្រ ហើយនៅជិតព្រែក Thuan An មានជំរៅជាង ៧ ម៉ែត្រ ។ ស្ថិតនៅក្នុងស្ថានភាពសមស្របបែបនេះ ស្រះចិញ្ចឹមត្រីបានកើនឡើងយ៉ាងលឿនក្នុងរយៈពេល ៦ ឆ្នាំចុងក្រោយនេះ ។ នៅពេលបច្ចុប្បន្ននេះ តំបន់ដែលរាក់ជាប់ទៅនឹងជ្រុងបឹងស្ទើរតែទាំងអស់ត្រូវបានប្រែក្លាយទៅជាស្រះចិញ្ចឹមត្រី ។ មន្ត្រីរដ្ឋាភិបាលគិតថា វារីវប្បកម្មគឺជាជំរើសមួយដើម្បីលើកកំពស់ប្រាក់ចំណូល និង កាត់បន្ថយសំពាធលើធនធាននៅបឹង ។ ប៉ុន្តែ វារីវប្បកម្មបានអភិវឌ្ឍន៍យ៉ាងលឿនដែលធ្វើឱ្យមានការជះឥទ្ធិពលយ៉ាងខ្លាំងលើបរិស្ថានធម្មជាតិ និង សង្គម ។

### គំរោង

នៅដំណាក់កាលទី១ (១៩៩៥-២០០១) នៃគំរោងស្រាវជ្រាវ ការគ្រប់គ្រងធនធានជីវសាស្ត្រនៅបឹងទឹកប្រៃ Tam Giang ត្រូវបានផ្តល់មូលនិធិដោយអង្គការ IDRC និង អនុវត្តដោយសកលវិទ្យាល័យ Hue កសិកម្ម និង រុក្ខា សកលវិទ្យាល័យវិទ្យាសាស្ត្រ និង នាយកដ្ឋានជលផលខេត្ត Thua Thien-Hue និង ដោយមានការជួយឧបត្ថម្ភថវិការបន្ថែមដោយ IDRC គំរោងបានចាប់ផ្តើមជាផ្លូវការនៅខែ ធ្នូ ២០០២ ដោយបញ្ចប់នៅខែ ធ្នូ ២០០៥ ។ ទីភ្នាក់ងារអនុវត្តសំរាប់ដំណាក់កាលទី២នេះគឺ អនុវត្តដោយសកលវិទ្យាល័យ Hue កសិកម្ម និង រុក្ខា សកលវិទ្យាល័យវិទ្យាសាស្ត្រ សកលវិទ្យាល័យជលផល Nga Trang វិទ្យាស្ថានស្រាវជ្រាវវារីវប្បកម្មលេខ៣ ដែលបច្ចុប្បន្នមានទីតាំងនៅ Nga Trang ។

### ការអនុវត្តការស្រាវជ្រាវដោយមានការចូលរួមនៅបឹងទឹកប្រៃ Tam Giang

ការស្រាវជ្រាវដោយមានការចូលរួម ដោយរួមបញ្ចូលប្រជាជនមូលដ្ឋាននៅក្នុងគ្រប់ដំណើរការៈ រៀនសូត្រពីស្ថានភាព ស្វែងរកនូវបញ្ហា ពិភាក្សាពីជំរើសផ្សេងៗ ជ្រើសរើសដំណោះស្រាយ រៀបចំ និង អនុវត្តសកម្មភាព វាយតំលៃ និង ផ្សព្វផ្សាយពីលទ្ធផល ។

ការស្រាវជ្រាវដោយមានការចូលរួមត្រូវបានគេប្រើដើម្បីរៀន និងស្វែងយល់ពីប្រព័ន្ធបរិស្ថានធម្មជាតិនៃសហគមន៍នៅបឹងទឹកប្រៃ Tam Giang និង ដើម្បីសិក្សាពីចរិតលក្ខណៈរបស់សហគមន៍ដែលរួមមាន ការចិញ្ចឹមជីវិតរបស់ពួកគេ ការធ្វើផែនការវារីវប្បកម្មនៅក្នុងតំបន់ ការហាមឃាត់ឆក់ត្រី និង លើកកំពស់ការគ្រប់គ្រងផ្លូវទឹក។ តាមរយៈនេះ ការប្រើយុទ្ធសាស្ត្រស្រាវជ្រាវ យើងអាចស្វែងយល់ពីការចិញ្ចឹមជីវិតផ្សេងៗ ទៅក្នុងសកម្មភាពកសិកម្ម និង វារីវប្បកម្មផ្សេងៗទៀតដូចជា ដាំថ្នាំជក់ ម្ទេស សណ្តែកដី និង សណ្តែក និង ការចិញ្ចឹមត្រីក្នុងបែរ និង ការចិញ្ចឹមត្រីក្នុងវាលស្រែនៅ Quang Thai (ជាឃុំមួយនៅក្នុងខេត្ត Thua Thien Hue)។

យុទ្ធសាស្ត្រស្រាវជ្រាវដោយមានការចូលរួមអាចឱ្យគំរោងដោះស្រាយនូវបញ្ហាបន្ទាន់នៅក្នុងសហគមន៍ដូចជា ការប្រកួតប្រជែងគ្នាប្រើប្រាស់ធនធាន ធ្វើផែនការនៅពេលដែលវារីវប្បកម្មមានការអភិវឌ្ឍន៍ខ្លាំង និង ផ្សព្វផ្សាយពីការសំរេចបានរបស់គំរោង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ។

**ផលប្រយោជន៍នៃការស្រាវជ្រាវដោយមានការចូលរួម**

ដោយប្រើនូវចំណេះដឹងដែលមាននៅមូលដ្ឋាន អ្នកភូមិខ្លួនឯងបានរកឃើញនូវបញ្ហាដែលមាននៅក្នុងសហគមន៍ និង ធ្វើការដោះស្រាយរួមគ្នាដោយផ្តល់ជាមតិយោបល់ដល់ការគ្រប់គ្រងសហគមន៍។ ការស្រាវជ្រាវដោយមានការចូលរួមក៏ធានាប្រជាជនដែលតែងតែមិនចូលរួមឱ្យចូលរួមនៅក្នុងការស្រាវជ្រាវដូចជាអ្នកដែលមានចំណេះដឹងទាប អ្នកដែលមានវប្បធម៌ខុសគ្នា ស្ត្រី និង ប្រជាជនក្រីក្រ។

ការស្រាវជ្រាវដោយមានការចូលរួមក៏បង្កើតនូវឱកាសសំរាប់ប្រជាជនមូលដ្ឋាន និង "អ្នកខាងក្រៅ" ដើម្បីធ្វើការជាមួយគ្នា។ វាក៏អាចជួយលើកកំពស់សមត្ថភាពក្នុងចំណោមសហគមន៍ មន្ត្រីមូលដ្ឋាន និង អ្នកស្រាវជ្រាវ។ ដោយមានការចូលរួមពីអ្នកជាប់ពាក់ពន្ធ័ផ្សេងៗនៅក្នុងការស្រាវជ្រាវ លទ្ធផលដែលទទួលបានគឺមានលក្ខណៈទូលំទូលាយ ដោយសារតែមានការវិភាគពីគ្រប់ជំនាញទាំងអស់ ហើយអាចឱ្យមានតុល្យភាពក្នុងពិភាក្សា និង សកម្មភាព។ ជៀងនេះទៅទៀត ការស្រាវជ្រាវដោយមានការចូលរួមជួយឱ្យមន្ត្រីមូលដ្ឋានយល់ដឹងពីការរស់នៅរបស់អ្នកភូមិ និង ទិសដៅចិញ្ចឹមជីវិតរបស់គាត់ និង រួមគ្នាអភិវឌ្ឍន៍ដំណោះស្រាយដែលមានអាចធ្វើបាន ងាយស្រួល និង មានប្រសិទ្ធិភាព។ វាក៏អាចជួយពួកគេឱ្យមានទស្សនៈកាន់តែទូលំទូលាយលើការគ្រប់គ្រងធនធានសហគមន៍។

**ការលំបាកដែលជួបប្រទះ**

ជាដំបូង ប្រជាជនគិតថាវាជាគំរោងជំនួយ ជាងសកម្មភាពស្រាវជ្រាវ ហើយគេសង្ឃឹមពីការជួយឧបត្ថម្ភខាងផ្នែកថវិការ។ បុគ្គលិកគិតថា ជាការសំខាន់ដែលយើងត្រូវពន្យល់ពីគោលបំណងនៃគំរោងដក់សមាជិកសហគមន៍។

ក្នុងចំណោមផលវិបាកដែលជួបប្រទះគឺ

- យុទ្ធសាស្ត្រស្រាវជ្រាវដោយមានការចូលរួមចាំបាច់ត្រូវមានការប្រឹងប្រែងពីដំបូងដើម្បីបង្កើតទំនាក់ទំនងល្អជាមួយអ្នកភូមិ
- មន្ត្រីរដ្ឋបាលមូលដ្ឋានជាទូទៅគឺមិនសូវដឹងពីយុទ្ធសាស្ត្រ និង វិធីសាស្ត្រស្រាវជ្រាវដោយមានការចូលរួម

- ការស្រាវជ្រាវដោយមានការចូលរួមទាមទារឱ្យអ្នកស្រាវជ្រាវទទួលបាននូវដំណេះដឹងថ្មី
- ជាទូទៅគឺមានការខ្វះខាតនូវបទពិសោធន៍ និង គំរូដែលល្អសំរាប់ធ្វើតាម
- ការស្រាវជ្រាវដោយមានការចូលរួមត្រូវបានគេគិតថាមានលក្ខណៈ " មិនផ្លូវការ " ដែលអាចចោទជាបញ្ហាលើ ការអាចយកជាការបាន
- វាអាចមានចំលើយជាច្រើនទៅលើសំណួរដូចគ្នាក្នុងការស្រាវជ្រាវដោយមានការចូលរួម
- ទិន្នន័យ "បរិមាណ"ដែលប្រមូលបានតាមរយៈការស្រាវជ្រាវដោយមានការចូលរួមអាចមានភាពលំអៀង

**បទពិសោធន៍ពីការផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ**

លទ្ធផលនៃការស្រាវជ្រាវដោយមានការចូលរួម អាចត្រូវបាបផ្សព្វផ្សាយតាមរយៈសិក្ខាសាលា និង កិច្ចប្រជុំនៅ គ្រប់ជាន់ថ្នាក់ក្រុមសហគមន៍ជាក់លាក់ណាមួយ ភូមិ ឃុំ ស្រុក ខេត្ត ទូទាំងប្រទេស និង ទៅក្រុមស្រាវជ្រាវផ្សេងៗទៀត។ ប្រពន្ធ័ផ្សព្វផ្សាយផ្សេងៗ អាចត្រូវបានគេប្រើៈ វិទ្យុ កាសែត ឯកសារដែលរួមមាន ពត៌មានដើម្បីបង្រៀន និង សំភារៈបំពាក់បំប៉នបច្ចេកទេស ឧទា. ដើម្បីផ្សព្វផ្សាយពីលទ្ធផលនៃការស្រាវជ្រាវអភិវឌ្ឍន៍វារីវប្បកម្មជាមួយ "អនុសហគមន៍ " អ្នកភូមិអាចមើលផែនទី តួរលេខ និង ទិន្នន័យនៅលើតារាងដែលសាមញ្ញ និង ងាយយល់។ ពត៌មានបែបនេះអាចបង្ហាញនៅគណៈកម្មាការប្រជាជនឃុំ និង នៅភូមិសំរាប់មន្ត្រីរដ្ឋបាលមូលដ្ឋាន និង អ្នកភូមិប្រើប្រាស់ដើម្បីធ្វើផែនការ។

នៅក្នុងការងារផ្សព្វផ្សាយ យើងត្រូវយកចិត្តទុដាក់លើវិធីសាស្រ្ត ទទួលបាននូវការឆ្លើយតប និង ធ្វើការសើរើលើ "លទ្ធផល " ក្នុងការកសាង និង ផ្សព្វផ្សាយ" គំរូ" សហគមន៍ដែលបានធ្វើការស្រាវជ្រាវគឺជាកន្លែងដែលល្អបំផុតសំរាប់ផ្សព្វផ្សាយនូវលទ្ធផល។

Ton That Chat គឺជានាយកនៃនាយកដ្ឋានវារីវប្បកម្មនៅសកលវិទ្យាល័យកសិកម្ម និង រុក្ខា Hue នៅប្រទេសវៀតណាម យើងអាចទាក់ទងតាមរយៈ < lagunhue@dng.vnn.vn >

# បទពិសោធន៍ និង ផលប្រយោជន៍នៃការវិភាគការចិញ្ចឹមជីវិត

*Michael Reynaldo, Orlando Arciaga, Fernando Gervacio និង Catherine Demesa*

## គំរោងការចិញ្ចឹមជីវិតដែលបរាជ័យ និង ការស្វែងយល់

លោក Jesem Gabatin និយាយថា "ខ្ញុំជាអ្នកនេសាទ ខ្ញុំមិនមែនជាអ្នកលក់ទេ" ដោយពន្យល់ពីមូលហេតុដែលធ្វើឱ្យគំរោងកែច្នៃសាច់អង្គការរបស់គេទទួលបរាជ័យ។ ជាប្រធាននៃអង្គការអ្នកនេសាទ បន្ទុកនៃការបរាជ័យគំរោងការចិញ្ចឹមជីវិតបានធ្លាក់នៅលើស្មារបស់គាត់។ រឿងរ៉ាវរបស់គាត់មិនមានតែមួយទេ គឺមាននៅគ្រប់ទីកន្លែងនៅក្នុងប្រទេសហ្វីលីពីន ទូទាំង ៥៥ កន្លែងដែលបានរកឃើញនៅក្នុងការសិក្សាដែលមានកម្មវិធីការគ្រប់គ្រងធនធានតំបន់ឆ្នេរតាមបែបសហគមន៍ នៅលើកំណាត់ផ្លូវគឺពោរពេញទៅដោយការបរាជ័យនៃគំរោងការចិញ្ចឹមជីវិត (មូលនិធិ Haribon, 2002)។ ក្នុងចំណោម ៥៥ កន្លែង មាន ៥៣ កន្លែងដែលមានផ្នែកអភិវឌ្ឍន៍ការចិញ្ចឹមជីវិតជាមួយនិង ការកសាងសមត្ថភាព។ គំនិតជាទូទៅគឺដើម្បីបង្កើនប្រាក់ចំណូលគ្រួសារ និង សុវត្ថិភាពស្បៀង និង កាត់បន្ថយសំពាធការនេសាទដើម្បីឱ្យធនធានប្រសើរឡើងវិញ។

ប៉ុន្តែ ភាគច្រើននៃអង្គការទាំងនោះធ្លាក់ទៅក្នុងអន្ទាក់ ដោយផ្តោតខ្លាំងពេលលើការបង្កើតប្រាក់ចំណូលដល់អ្នកនេសាទ ហើយដែលការគ្រប់គ្រងធនធាន និង ការរៀបចំសហគមន៍តែងតែមិនអើពើរ។ អ្នកនេសាទត្រូវបានគេ "បង្ខំ" ឱ្យធ្វើការចិញ្ចឹមជីវិតដែលគាត់មិនចាប់អារម្មណ៍ និង គ្មានសមត្ថភាព។ ជាងនេះទៅទៀត គំរោងការចិញ្ចឹមជីវិតជាទូទៅគឺមិនមានលក្ខណៈធំល្មមដើម្បីបង្វែអ្នកនេសាទពីការនេសាទទេ។ កត្តាទាំងនេះគឺជាមូលហេតុចំបងនៃការបរាជ័យសហគ្រាសធុនតូចទាំងនេះ។

នៅពីរ បីឆ្នាំមុន អង្គការទាំងនេះបានរកការស្វែងយល់ពីភាពសាំញ៉ាំ និង ទំនាក់ទំនងដ៏ចាក់ច្រេះរវាង សង្គម និង រូបបរិស្ថានជាពិសេសសង្កត់ធ្ងន់លើការងាយរងគ្រោះ ដែលការសំរេចចិត្តពីយុទ្ធសាស្ត្រចិញ្ចឹមជីវិតត្រូវបានធ្វើ។ ដោយសង្កត់ធ្ងន់លើវិធីសាស្ត្រចូលរួម អ្នកអនុវត្តការគ្រប់គ្រងធនធានតំបន់ឆ្នេរបានរកឃើញនូវការយល់ដឹងកាន់តែប្រសើរឡើងថែមទៀតពីកត្តាផ្សេងៗ ដែលជះឥទ្ធិពលលើការចិញ្ចឹមជីវិតរបស់ប្រជាជន ដោយរាប់បញ្ចូលនូវជំរើសផ្សេងៗសំរាប់ពួកគាត់។

អង្គការមិនមែនរដ្ឋាភិបាលហ្វីលីពីនមួយ (មូលនិធិ Haribon) ទទួលបាននូវបទពិសោធន៍ដោយធ្វើការជាមួយនឹងសហគមន៍តំបន់ឆ្នេរនៅ Bolinao, Pangasinan ដើម្បីធ្វើគំរោងការគ្រប់គ្រងធនធានតំបន់ឆ្នេរតាមបែបសហគមន៍ដោយមានការជួយឧបត្ថម្ភមូលនិធិដោយ IDRC។ ការអប់រំពីបរិស្ថាន ការរៀបចំសហគមន៍ និង កិច្ចខិតខំប្រឹងប្រែងនានាបានបង្កើតនូវអង្គការប្រជាជន៥ នៅចុងដំណាក់កាលទី១ ក្នុងឆ្នាំ ១៩៩៧។ ដោយអង្គការប្រជាជនទាំងនេះបានទទួលជោគជ័យលើការសំរបសំរួលផែនការអភិវឌ្ឍន៍តំបន់ឆ្នេរ និង មានការជួយឧបត្ថម្ភសំរាប់គំរោងរបស់ពួកគេពីរដ្ឋាភិបាល ពួកគេក៏មានបញ្ហាលើរចនាសម្ព័នដែលធ្វើឱ្យមានការបរាជ័យក្នុងការអនុវត្តរបស់គេ។

បញ្ហាចំបងបំផុតដែលធ្វើឱ្យការអនុវត្តមិនបានល្អគឺមធ្យោបាយដែលគំរោងការចិញ្ចឹមជីវិតទាំងអស់បានធ្វើ។ ពួកគេដឹងថា កំរិតនៃការចូលរួមរបស់ប្រជាជននៅក្នុងគំរោងគឺមានការជះឥទ្ធិពលដោយផ្ទាល់លើជោគជ័យ និង បរាជ័យរបស់គំរោង ហើយការអភិវឌ្ឍន៍ការចិញ្ចឹមជីវិតអាចនឹងត្រូវគេដោះស្រាយនៅកំរិតអ្នកគ្រប់គ្រង ជាងតាមរយៈសហករណ៍ដែលមានរចនាសម្ព័នផ្លូវការ។

បទពិសោធន៍បានមកពីដំណាក់កាលទី១ មូលនិធិ Haribon និង សហគមន៍បានស្វែងយល់កាន់តែច្បាស់ពីស្ថានភាពដើម្បីរៀបចំនូវការធ្វើអន្តាគមន៍ការចិញ្ចឹមជីវិតដែលសមស្រប។ ពួកគេចង់ដឹង ឧទា. ប្រភពសំរាប់ការចិញ្ចឹមជីវិត និង ការអនុវត្តន៏នៅកំរិតគ្រួសារ និង ការជំពាក់ទាក់ទិនដើម្បីធានាការចិញ្ចឹមជីវិតដោយនិរន្តរភាព និង ការគ្រប់គ្រងធនធានជលផល។ ពួកគេក៏ពិនិត្យលើកត្តាសង្គម វប្បធម៌ និង សេដ្ឋកិច្ចចាំបាច់ក្នុងការអនុវត្តន៏ការគ្រប់គ្រងធនធាន ដែលរួមមាន រកឱ្យឃើញនូវកំរិតនៃរចនាសម្ព័នដែលសកម្មភាពការចិញ្ចឹមជីវិត ការគ្រប់គ្រងធនធានដែលអាចគ្រង់គ្រងបាន។

ពួកគេបានធ្វើការលើកកំពស់និរន្តរភាពរបស់សហគមន៍តាមរយៈការបង្កើតសហគមន៍ និង សកម្មភាពអភិវឌ្ឍន៏ការចិញ្ចឹមជីវិតឱ្យមានប្រសិទ្ធភាពមានរយៈពេល ៣ ឆ្នាំ។ ពួកគេមានការគ្រប់គ្រងល្អ លើកកំពស់លក្ខណៈវិនិច្ឆ័យ និង ការអនុវត្តន៏នៃសកម្មភាពការចិញ្ចឹមជីវិត លើកកំពស់សមត្ថភាពម្នាក់ៗ និង ក្រុម និង បញ្ចូលនូវចលករដែលធ្វើឱ្យប្រសើរឡើង។ ការងារនេះរួមមានការបំពាក់បំប៉នប្រធានសហគមន៏ឱ្យក្លាយទៅជា "អ្នកវិទ្យាសាស្ត្រភូមិ " ដែលអាចប្រមូល និង វិភាគពត៌មានពីសកម្មភាពការចិញ្ចឹមជីវិត និង ស្ថានភាពសេដ្ឋកិច្ចសង្គម និង វប្បធម៌។ ប្រធានសហគមន៏ទាំងនេះនឹងក្លាយទៅជាអ្នករៀបចំសហគមន៏មូលដ្ឋាន និងក្លាយទៅជាដៃគូររបស់បុគ្គលិក Haribon ។

ដោយសារតែលទ្ធផលនៃការវិភាគការចិញ្ចឹមជីវិត និង ការងាររៀបចំ គំនិតការអភិវឌ្ឍន៏ការចិញ្ចឹមជីវិតមួយត្រូវបានបង្កើតដោយអ្នកនេសាទនៅក្នុងភូមិ Victory ។ ដែលគេហៅថា ការអភិវឌ្ឍន៏វារីវប្បកម្មចំរុះដោយនិរន្តរភាព (SIAFDEV) វារួមបញ្ចូលនូវគំរោងការចិញ្ចឹមជីវិតដែលពឹងផ្អែកលើធនធានដែលមាននៅលើដី និង សមុទ្រ ទៅក្នុងគំរោងគ្រប់គ្រងធនធានដោយនិរន្តរភាព។ ពួកគេក៏កំពុងគ្រប់គ្រងមូលនិធិបរិស្ថានដែលអនុញ្ញាតិពួកគេរក្សាបាននូវកម្មវិធីគ្រប់គ្រងធនធាននៅក្នុងបរិស្ថាននយោបាយ។

**ផលប្រយោជន៏នៃការវិភាគការចិញ្ចឹមជីវិត**

តាមរយៈបទពិសោធន៏របស់ Haribon និង សហគមន៏ដែលគេធ្វើការជាមួយ ការវិភាគការចិញ្ចឹមជីវិតមានគោលបំណងសំខាន់គឺបញ្ជាក់នូវរបៀបដែលពួកគេគិតពីភាពក្រីក្រ និង មូលហេតុរបស់វា និង ជាគន្លឹះសំរាប់វិភាគ រៀបចំកម្មវិធី អនុវត្ត និង វាយតំលៃ។ ដោយប្រើនូវចំណេះដឹងដែលមាននៅមូលដ្ឋាន ពួកគេមានទស្សនៈអំពីឳកាសកាន់តែទូលំទូលាយ ហើយបានជះឥទ្ធិពល និង សមស្របតាមអាទិភាពការចិញ្ចឹមជីវិតរបស់ប្រជាជន។ វាក៏អាចឱ្យពួកគេដាក់នូវអាទិភាពរបស់ប្រជាជន និង ខ្លួនគេឱ្យកាន់តែច្បាស់នៅក្នុងការវិភាគ និង ការបង្កើតទិសដៅ។ ជាពិសេសទៅទៀត ការវិភាគពីការចិញ្ចឹមជីវិតជួយនាំទៅរកនូវគំរោងដែលឆ្លើយតបទៅនឹងការចិញ្ចឹមជីវិត។

*ពិនិត្យមើលបរិបទ និង ទំនាក់ទំនង* - ជួយ "រៀបចំ " កត្តាទាំងឡាយដែលរារាំង ឬក៏ផ្តល់ឱកាស និង ពីរបៀបនៃកត្តាទាំងនេះទាក់ទងគ្នាទៅវិញទៅមក។

*រកនូវយុទ្ធសាស្ត្រការចិញ្ចឹមជីវិត "សមស្រប " និង "ប្រឆាំងគ្នា "* - បង្កើតនូវអនុសាសន៏លើការលើកកំពស់ " ភាពសមស្របរវាង" គំរោងថ្មី និង អាទិភាពការចិញ្ចឹមជីវិតរបស់ប្រជាជន ឬ ដោះស្រាយជំលោះរវាងពួកគេ។ វាក៏សំរបសំរួលលើការស្វែងយល់ និង រៀនសូត្រ ដូច្នេះរបៀបផ្លាស់ប្តូរជាវិជ្ជមានត្រូវបានលើកកំពស់ និង ការផ្លាស់ប្តូរអវិជ្ជមានត្រូវបានកាត់បន្ថយ។

លើកទឹកចិត្តដល់គំនិតថ្មី - លើកទឹកចិត្តដល់អ្នកប្រើប្រាស់ឱ្យដឹង និង គិតពីការរួមផ្សំ ឬ ដាក់ជំនួសនូវធនធានដែលមានដើម្បី

សំរេចបាននូវលទ្ធផលដែលចង់បាន។

*បង្កើតនូវគំនិតដើម្បីលើកកំពស់ការរៀបចំគំរោង-* ការវិភាគពីការចិញ្ចឹមជីវិតបានផ្តល់នូវវិធីសាស្រ្តដ៏ល្អដើម្បីរៀបរាប់ និង វិភាគប្រពន្ធ័ការចិញ្ចឹមជីវិតនៃគ្រួសារ និង សហគមន៏នៃតំបន់ឆ្នេរ។ វាក៏ជួយដល់ការស្វែងយល់ពីយុទ្ធសាស្រ្តដែលសហគមន៏បានទទួលយកដើម្បីសំរេចបានទិសដៅរបស់ខ្លួន និង ក្នុងការធ្វើផែនការសំរាប់យុទ្ធសាស្រ្តចិញ្ចឹមជីវិតបន្តទៀត។

កាត់បន្ថយគំលាតទំនាក់ទំនង ម៉ាក្រូ និង មីក្រូ- ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃគោលនយោបាយម៉ាក្រូ និង ការជះឥទ្ធិពលរបស់វាលើជំរើសការចិញ្ចឹមជីវិតរបស់សហគមន៏។ វាក៏ផ្តោតលើភាពចាំបាច់នូវការអភិវឌ្ឍន៏គោលនយោបាយមានករិតខ្ពស់ និង ធ្វើផែនការផ្អែកតាមបទពិសោធន៏ និង ពតិមានលំអិតទទួលបានពីមូលដ្ឋាន។

*សង្កត់លើទំនាក់ទំនងរវាងការចិញ្ចឹមជីវិត និង ការគ្រប់គ្រងធនធាន-* សង្កត់លើភាពចាំបាច់នៃការគ្រប់គ្រងធនធានដើម្បីផ្តល់នូវការចិញ្ចឹមជីវិតសំរាប់អ្នកនៅតំបន់ឆ្នេរ ជាជៀង ផ្តោតតែទៅលើគំរោងជំរើសការចិញ្ចឹមជីវិតដែលពួកគេមិនបានរៀបចំខ្លួនទេនោះ ។ ការគ្រប់គ្រងធនធានគឺមិនត្រឹមតែការធ្វើឱ្យប្រសើរឡើងនូវធនធានធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែវាជាការបូកបញ្ចូលដើម្បីសំរេចបានការចិញ្ចឹមជីវិតដោយនិរន្តរភាព សមុទ្រគឺអាយុជីវិតរបស់សហគមន៏ និង ជាផ្នែកមួយនៃទស្សនៈវិស័យពីការចិញ្ចឹមជីវិតដោយនិរន្តភាព។

ឯកសារយោង

Haribon Foundation 2002 *Community base Mechanisma and Methods for Coastal Livelihood Development Monitoring and Evaluation Summary Report from Year 1999-2001.* Pangasinan, Philippines: Haribon Foundation.

Michael Reynaldo គឺជាអ្នកសំរបសំរួលនៃបណ្តាញ LeaRN (CBCRM Learning and Research Network), មជ្ឈមណ្ឌលធនធាននៃ CBCRM, ទីក្រុង Quezon, ប្រទេស ហ្វីលីពីន។ យើងអាចទាក់ទងតាមរយៈ < mikereynaldo@cbcrmlearning.org

# បទពិសោធន៍ការអនុវត្តន៍ PRA ក្នុងការវិភាគការចិញ្ចឹមជីវិត

*Nguyen Thi Thuy*

## ការវាយតំលៃដោយមានការចូលរួម (PRA) នៅក្នុងបរិបទនៃប្រទេសវៀតណាម

ការវាយតំលៃដោយមានការចូលរួមគឺជាវិធីសាស្ត្រមួយដើម្បីរៀនសូត្រពីការចិញ្ចឹមជីវិតរបស់សហគមន៍ ដែលត្រូវបានគេចាប់ផ្តើមប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងកម្មវិធី និង គំរោងអភិវឌ្ឍន៍នៅក្នុងប្រទេសវៀតណាម ។ ភាពខ្លាំងរបស់ PRA គឺវាផ្តល់ឱកាសឱ្យកសិករចូលរួមនៅក្នុងដំណើរការស្រាវជ្រាវដើម្បីនាំយកនូវលទ្ធិប្រជាធិបតេយ្យពេញលេញ ដោយសារតែគេចែករំលែកនូវពតិមាន និង ការយល់ដឹងរបស់ពួកគេ ។ ដោយចូលរួមនៅក្នុងដំណើរការចាប់ពីពេលចាប់ផ្តើម អ្នកធ្វើ PRA មានឱកាសរៀននូវយុទ្ធវិធី និង វិធាន ( Tool) ថ្មី ។ PRA ក៏បានបង្កើតលក្ខខណ្ឌសំរាប់អ្នកជាប់ពាក់ពន្ឋ័ទាំងអស់យល់កាន់តែច្បាស់នូវរបៀបដែលពួកគេកំពុងរស់នៅ និង ធ្វើការ និង រកនូវបញ្ហាដែលសហគមន៍ជួបប្រទះ និង ស្វែងរកដំណោះស្រាយដែលកសិករខ្លួនឯងបានអភិវឌ្ឍន៍តាមរយៈគំរោងដើម្បីឆ្លើតតបនឹងសេចក្តីត្រូវការរបស់សហគមន៍ ។

នៅពេលអនាគត កសិករនឹងអាចចូលរួមនៅក្នុងការអនុវត្តន៍ និង វាយតំលៃគំរោងឱ្យកាន់តែមានប្រសិទ្ធិភាព ។ ហេតុដូច្នេះគំរោងអភិវឌ្ឍន៍ដែលជោគជ័យពឹងផ្អែកលើដំណើរការជោគជ័យរបស់ PRA ។ ប៉ុន្តែ យុទ្ធវិធីវិភាគការចិញ្ចឹមជីវិតដោយមានការចូលរួមត្រូវបានគេយកមកអនុវត្តទូលំទូលាយទើបតែនៅពេលថ្មីៗប៉ុណ្ណោះ ហើយមិនមានស្ថាប័ន និង អង្គការណាច្រើនទេ ជាពិសេស នៅប្រទេសវៀតណាមតែម្តង ។ ដូច្នេះមានឱកាសយ៉ាងច្រើនសំរាប់រៀនយកបទពិសោធន៍ ។

## ការអនុវត្តន៍ PRA


ការធ្វើគំរូភូមិ

ក្នុងការធ្វើផែនការ និង រៀបចំកសាងសមត្ថភាព ឬ វគ្គបំពាក់បំប៉ន យើងត្រូវគិតពីគោលបំណង រៀបចំដំណើរការដែលទាក់ទង សកម្មភាព និង វិធីសាស្ត្រ និង បញ្ជាក់ពីរយៈពេលមុនពេលអនុវត្ត និង ដំណើរការស្រាវជ្រាវជាក់ស្តែង ។ ក្នុងការជ្រើសរើសសមាជិកក្រុមធ្វើ PRA សមាជិកគួរមានចំនួនសមស្របដើម្បីធានាថា អ្នកជាប់ពាក់ពន្ឋ័ទាំងអស់បានចូលរួម ។ នៅពេលដែលសមាជិកក្រុមបានជ្រើសរើសហើយ សហការីដែលមានបទពិសោធន៍ខាងការវិភាគការចិញ្ចឹមជីវិតដោយមានការចូលរួម អាចធ្វើការជាមួយក្រុមដើម្បីសំរេចការងារឱ្យបានជោគជ័យ ។ យើងគួរកត់សំគាល់ថា ពេលវេលា និង ទីកន្លែងនៃការអនុវត្តន៍ PRA គួរតែសមស្របសំរាប់សហគមន៍ គួរធ្វើនៅពេលដែលកសិករទំនេរ ។

ការពិភាក្សាជាមួយកសិករគួរតែចងក្រងជាឯកសារ និង ស្វែងយល់ពីទស្សនៈរបស់សហគមន៍ ។ ក្រុមគួរតែចំណាយពេលគ្រប់គ្រាន់រៀនសូត្រពីប្រពៃណី និង ទំនៀមទំលាប់របស់មូលដ្ឋាន ។ ពួកគេគួរផ្តល់ឱកាសឱ្យកសិករនៅក្នុងសហគមន៍រៀនសូត្រពីគោលបំណង និង ដំណើរការរបស់ PRA តាមរយៈការពន្យល់ឱ្យបានច្បាស់ ដូច្នេះសហគមន៍អាចចូលរួមយ៉ាងមានប្រសិទ្ធិភាព និង ផ្តល់

នូវពត៌មានដែលទាក់ទង។ ក្រុម PRA អាចផ្តល់នូវគោលការណ៍ណែនាំក្នុងការអនុវត្តន៍ដំណើរការស្រាវជ្រាវ និង ក៏ជាឱកាសរបស់កសិករក្នុងការអនុវត្តន៍នូវវិធាន (Tool) មុនពេលការងារចាប់ផ្តើម។

PRA គួរអនុវត្តនៅពីរ ឬ បី កន្លែង។ បើសិនជាការស្រាវ ជ្រាវបានធ្វើនៅពេលព្រមៗគ្នានៅគ្រប់តំបន់ទាំងអស់ ឬក៏ពីកន្លែងមួយទៅកន្លែងមួយទៀត យើងគួរគិតគូរពីសុក្រិតភាពនៃពត៌មាន និង ទិន្នន័យដែលប្រមូលមក។ បើសិនជាចាំបាច់ត្រូវចែកជាក្រុមតូចៗដើម្បីធ្វើ PRA នៅពេលតែមួយ ត្រូវមានសមាជិកនៅក្នុងក្រុមណាម្នាក់យល់ និង អាចប្រើ Tools ទាំងនេះបាន។ ប្រធានក្រុមត្រូវត្រួតពិនិត្យ ដំណើរការ និង លទ្ធផលដែលលេចចេញមក និង ធ្វើអនុសាសន៍ និង កែសំរួលតាមដែលអាចធ្វើទៅបាន។ ការស្រាវជ្រាវគួរមានរយៈពេលគ្រប់គ្រាន់ដើម្បីឱ្យគេប្រមូល និង ផ្ទៀងផ្ទាត់ពត៌មាន និង ទិន្នន័យ។ ប៉ុន្តែមិនគួរយូរពេក ដែលធ្វើឱ្យសមាជិកក្រុមមិនអាចចូលរួមនៅក្នុងដំណើរការទាំងមូល ដោយសារពួកគេអាចជាប់រវល់ធ្វើអ្វីផ្សេងទៀត។

យើងគួរផ្តោតការពិចារណាលើដំណើរការរៀបចំ និង ការជ្រើសរើស និង ចំនួន Tools ដែលត្រូវប្រើ។ វាជាការសំខាន់ដែលត្រូវអនុញ្ញាតិឱ្យសមាជិកសហគមន៍បន្តចូលរួម។ ពត៌មាន និង ទិន្នន័យដែលប្រមូលបានពីសហគមន៍គួរតែផ្ទៀងផ្ទាត់ភ្លាមៗដើម្បីធានានូវសុក្រិតភាព។ បន្ទាប់ពីចំណាយពេលយ៉ាងច្រើននៅក្នុងសហគមន៍ ក្រុម PRA គួរតែបន្តទាក់ទង និង ផ្តល់ពត៌មានដល់កសិករពីលទ្ធផល។



កំពុងធ្វើវិនិច្ឆ័យក្រុម

**ទស្សនៈវិស័យ និង ផលប្រយោជន៍នៃយុទ្ធវិធី PRA**

ថ្វីត្បិតតែយុទ្ធវិធី PRA នៅថ្មីសំរាប់ប្រទេសវៀតណាម ទស្សនៈវិស័យនៃការបង្កើនការប្រើប្រាស់គឺមានលក្ខណៈជាវិជ្ជមាន។ ស្ថាប័នរដ្ឋាភិបាលមួយចំនួនដែលទាក់ទងនឹងកម្មវិធីកាត់បន្ថយភាពក្រីក្រនៅជាន់ទាប បានចាប់ផ្តើមប្រើប្រាស់យុទ្ធវិធី PRA។ ច្បាប់របស់រដ្ឋាភិបាលនាពេលបច្ចុប្បន្ន ដែលកំពុងលើកកំពស់ប្រជាធិបតេយ្យ ក៏បានផ្តោតលើវិធីសាស្ត្រចូលរួមក្នុងការប្រមូលពត៌មានដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ និង ឆ្លើយតបតាមតំរូវការរបស់សហគមន៍ក្រីក្រ។

ការងាររបស់ការិយាល័យទឹកភ្លាវ និង វារីវប្បកម្មសមុទ្រ (SUMA) បានទទួលផលប្រយោជន៍ពី PRA ក្នុងការធ្វើគំរោងផែនការរបស់សហគមន៍បានសមស្រប និង កសាងទំនាក់ទំនងជាមួយប្រជាជនមូលដ្ឋាន។ តាមបទពិសោធន៍ យុទ្ធវិធី PRA មានប្រសិទ្ធិភាពបំផុត បើសិនជាពួកគេបញ្ចូលគ្រប់អ្នកជាប់ពាក់ពន្ធ័ទាំងអស់ ទាំងបុគ្គលិកបច្ចេកទេស និង ភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ ក៏ដូចជា ដៃគូរផ្សេងៗ។




ការវាយតំលៃសេចក្តីត្រូវការ

*Ngugen Thi Thuy* គឺជាអ្នកសេដ្ឋកិច្ចសង្គម ធ្វើការជាមួយគំរោងជួយគាំទ្រដល់វិស័យជលផលរបស់ DANIDA មានទីតាំងនៅក្នុងក្រសួងជលផលវៀតណាម ។ យើងអាចទាក់ទងតាមរយៈ < ntthuy.suma@fsps.com.vn >។

# បទពិសោធន៍ពីការវិភាគការចិញ្ចឹមជីវិត និង PRA នៅតំបន់ផ្កាថ្មបំរុងទុក Trao

*Nguyen Viet Vinh*

## ការគ្រប់គ្រងនៅមូលដ្ឋាន និង ការចិញ្ចឹមជីវិតរបស់សហគមន៍

សម្ព័ន្ធភាពជីវិតសត្វសមុទ្រអន្តរជាតិ (International Marinelife Alliance "IMA") នៃប្រទេសវៀតណាម បច្ចុប្បន្នកំពុងសំរបសំរួលបង្កើតតំបន់ផ្កាថ្មបំរុងទុក គ្រប់គ្រងដោយសហគមន៍មូលដ្ឋាននៅឃុំ Van Hung ស្រុក Van Ninh ខេត្ត Khanh Hoa។ គំរោងមានទិសដៅជួយដល់ប្រជាជនមូលដ្ឋានឱ្យជួយគ្រប់គ្រង និង ការពារធនធានតំបន់ឆ្នេររបស់គេ- ផ្កាថ្ម និង ប្រពន្ធ័អេកូឡូស៊ីដែលពាក់ពន្ធ័ តាមរយៈការអនុវត្តន៍វារីវប្បកម្មសមុទ្រ និង ការនេសាទដោនិរន្តរភាព ដូច្នេះស្ថានភាពសេដ្ឋកិច្ចសង្គម ត្រូវបានអភិវឌ្ឍន៍ និង លើកកំពស់។

ជាអង្គការអភិរក្សសមុទ្រ IMA បានគិតថាប្រជាជនមូលដ្ឋានគឺជាកត្តាសំខាន់នៃកិច្ចខិតខំអភិរក្ស និង គំរោងអាចទទួលជោគជ័យបានអាស្រ័យលើការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់សហគមន៍មូលដ្ឋាន។ តាមរយៈសកម្មភាពលើកកំពស់ការយល់ដឹង និង PRA ប្រជាជនមូលដ្ឋានបានយល់ដឹងពីឥទ្ធិពលនៃការអភិរក្សសមុទ្រលើការចិញ្ចឹមជីវិតរបស់ពួកគេដែលពឹងផ្អែកលើការ នេសាទ និង វារីវប្បកម្ម។ ជាលទ្ធផល ពួកគេបានប្រឆាំងនឹងគំរោងបង្កើតតំបន់បំរុងទុកនេះ ដោយគេដឹងថា វាក៏ជះឥទ្ធិពលលើការចិញ្ចឹមជីវិតរបស់ប្រជាជនមូលដ្ឋាន ជាពិសេស អ្នកដែលនេសាទនៅជិតៗឆ្នេរ។ នាពេលបច្ចុប្បន្ន បញ្ហាអភិរក្ស និង ការចិញ្ចឹមជីវិតនៅតំបន់គំរោងគឺ:

- វារីវប្បកម្មសមុទ្រ ជាពិសេស បង្កងសមុទ្រ ហាក់ដូចជាគ្មាននិរន្តរភាព ដែលអាចជះឥទ្ធិពលជាអវិជ្ជមានដល់ការរកប្រាក់ចំណូលរបស់ប្រជាជន ៥០០ គ្រួសារ និង ធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចនៃប្រជាជនប្រហែល ១ ម៉ឺននាក់នៅក្នុងសហគមន៍ទាំងមូល កាន់តែយ៉ាប់យ៉ឺន។
- ធនធានតំបន់ឆ្នេរថយចុះកាន់តែខ្លាំង ដែលធ្វើឱ្យការនេសាទកាន់តែពិបាក
- តំបន់ដីសើមមិនត្រូវបានគេប្រើប្រាស់តាមលក្ខណៈវិទ្យាសាស្ត្រទេ ដែលរារាំងដល់ជំរើសការចិញ្ចឹមជីវិតដល់ប្រជាជនមូលដ្ឋាន
- ប្រជាជនមូលដ្ឋានគឺក្រីក្រ និង ឱកាសការងារកាន់តែថយទៅ។

## ទស្សនៈវិស័យរបស់ IMA លើសកម្មភាពចិញ្ចឹមជីវិត

បញ្ហាការចិញ្ចឹមជីវិតតែងតែមានទំនាក់ទំនងជាមួយនឹងធនធានធម្មជាតិ ក៏ដូចជាពីស្ថានភាពសេដ្ឋកិច្ចសង្គម ដូច្នេះទាមទារឱ្យមានការឆ្លើយតបពីសង្គម។ សកម្មភាពចិញ្ចឹមជីវិត (រាប់បញ្ចូលទាំង PRA) គួរតែគិតពីប្រជាជន និង ផ្អែកលើសហគមន៍។ ប្រជាជនទាំងអស់គួរតែចូលរួមឱ្យបានពេញលេញ និង ទទួលផលប្រយោជន៍ស្មើរគ្នា។ ប្រជាជនគួរតែចូលរួមចាប់ពីដំណាក់ដំបូង និង នៅគ្រប់ដំណាក់កាលទាំងអស់នៃគំរោង- ស្វែងយល់ និង ពិភាក្សាបញ្ហា អនុវត្ត និង វាយតំលៃដំណើរការ។ ដំណោះស្រាយណាមួយក៏ដោយត្រូវតែផ្តល់ និង សំរេចដោយប្រជាជនមូលដ្ឋាន។

ទស្សនៈវិស័យរបស់ IMA អាចកំណត់ដូចខាងក្រោមៈ

- ថែរក្សាការចិញ្ចឹមជីវិតបច្ចុប្បន្នៈ តំបន់អភិរក្សផ្កាថ្ម Trao គឺមិនត្រឹមតែមានសារសំខាន់សំរាប់តែអភិរក្សប៉ុណ្ណោះទេ ប៉ុន្តែវាជារបាំងការពារដល់ដែនទឹកដែលប្រើដើម្បីចិញ្ចឹមបង្កងសមុទ្រ។ ការរិចរិលមៃផ្កាថ្ម Trao នឹងជះឥទ្ធិពលដោយផ្ទាល់ និង អវិជ្ជមានដល់ការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន។

- កែទំរង់ការចិញ្ចឹមជីវិតបច្ចុប្បន្នឈានទៅរកការអភិវឌ្ឍន៏ដោយនិរន្តរភាពៈ ការចិញ្ចឹមបង្កងសមុទ្រ និង ខ្យង គឺ ទទួលរងការគំរាមកំហែងដោយសារតែ ដង់ស៊ីតេខ្ពស់ ប្រើប្រាស់ចំណីស្រស់ៗ និង ខ្វះបច្ចេកទេសសមស្រប។ លទ្ធផល និង អនុសាសន៏ ការវាយតំលៃការជះឥទ្ធិពលបរិស្ថាន និង សេដ្ឋកិច្ចសង្គមនៃការការចិញ្ចឹមបង្កងសមុទ្រ ត្រូវបានរាយការណ៍ត្រលប់ទៅសហគមន៍ និង មន្ត្រីមូលដ្ឋានវិញដើម្បីលើកកំពស់ការយល់ដឹងរបស់ពួកគេពីតុល្យភាពរវាង វារីវប្បកម្ម និង បរិស្ថាន។

- អភិវឌ្ឍន៏ជំរើសការចិញ្ចឹមជីវិតថ្មីដែលមិនប៉ះពាល់ដល់បរិស្ថាន-ដោយផ្តោតលើក្រុម "មានគ្រោះថ្នាក់បំផុត"ដែលទទួលរងឥទ្ធិពលនៃការបង្កើតតំបន់បំរុងទុក និង ក្រុមអ្នកនេសាទ និង ស្ត្រីដែលក្រីក្រ វេទិកាការចិញ្ចឹមជីវិតត្រូវបានធ្វើឡើងដើម្បីពិភាក្សាលើជំរើសការចិញ្ចឹមជីវិតដែលមិនប៉ះពាល់ដល់បរិស្ថាន។ បន្ទាប់ពីវេទិកានេះ ជំរើសការចិញ្ចឹមជីវិតដែលសមស្របបំផុតត្រូវបានគេជ្រើសរើស និង អនុវត្ត ឧទា. អ្វីដែលត្រូវការថវិការតិច និង ប្រជាជនក្រីក្រទទួលផលប្រយោជន៏ដោយផ្ទាល់។

**បទពិសោធន៏**

- វាជាពិបាកនឹងធ្វើឱ្យមានតុល្យភាពការប្រើប្រាស់ធនធានធម្មជាតិ និង បញ្ហាការចិញ្ចឹមជីវិតនៅក្នុងតំបន់ឆ្នេរដោយសារតែទំនាស់តែងតែកើតមានជារឿយៗ។ នេះគឺជាបញ្ហាសង្គម និង វាអាចដោះស្រាយបានទាល់តែមានការចូលរួមពេញលេញពីសហគមន៏ និង សំរបសំរួលជាមួយនឹងរដ្ឋបាលមូលដ្ឋាន

- រាល់សកម្មភាព និងពតិមានដែលទាក់ទងនឹងការចិញ្ចឹមជីវិត គួរតែមានតម្លាភាព និង ពិភាក្សាដោយប្រជាជនមូលដ្ឋានដែលជាអ្នកជ្រើសរើសនូវដំណោះស្រាយ និង ធ្វើសកម្មភាពដោយខ្លួនឯង។ សកម្មភាពទាំងនេះគួរតែរាយការណ៏ដល់រដ្ឋបាលមូលដ្ឋានដើម្បីពិគ្រោះយោបល់ និង ទទួលបានការជួយឧបត្ថម្ភគោលនយោបាយពីគេ។

- សកម្មភាពលើកកំពស់ការយល់ដឹងគួរតែអនុវត្តជាទៀងទាត់ជាមួយសកម្មភាពគំរោងដ៏ទៃទៀត

- ប្រជាជនក្រីក្រ ជាពិសេសក្រុមស្ត្រី និង គ្រោះថ្នាក់បំផុត គួរតែគិតគូរមុនគេ

- ការវិភាគគឺជាការចាំបាច់ដើម្បីឱ្យយល់ពីភាពងាយរងគ្រោះនៃការចិញ្ចឹមជីវិត

ការប្រឹងប្រែង និង ការលំបាក

- ការរកបានដោយសេរីនៃធនធានតំបន់ឆ្នេរ និង សមុទ្រអាចនាំទៅរកការធ្វើអាជីវកម្មហួសកំរិត និង ជំលោះក្នុងចំណោមអ្នកប្រើប្រាស់ធនធានធម្មជាតិ
- ជាទូទៅ វារីវប្បកម្មទាមទារឱ្យមានការធ្វើវិនិយោគដ៏ច្រើន អ្នកមានតែងតែទទួលបាននូវកន្លែងដែលល្អ មានលក្ខណៈប្រសើរ ការអភិវឌ្ឍន៏តំបន់ទាំងនេះអាចនាំពួកគេមានឥទ្ធិពលលើអាជ្ញាធរមូលដ្ឋាន និង រារាំងប្រជាជនក្រីក្រមិនឱ្យប្រើប្រាស់នូវធនធានទាំងនេះ
- រដ្ឋាភិបាលកំពុងលើកកំពស់ការអភិវឌ្ឍន៏វារីវប្បកម្ម ប៉ុន្តែមិនទាន់មានគោលនយោបាយលើការសំអាតជាតិកខ្វក់ក្នុងទឹក និង ការការពារបរិស្ថាន
- មានពត៌មានទីផ្សារតិចតួចពីផលិតផលវារីវប្បកម្ម ដូចជា គ្រុំ បៃតង សារាយសមុទ្រ និង ងាវ
- ចំណេះដឹង និង បទពិសោធន៏ការគ្រប់គ្រងតំបន់ឆ្នេរចំរុះ គឺនៅមានកំរិត
- ការវាយតំលៃពីការជះឥទ្ធិពលនៃវារីវប្បកម្មលើបរិស្ថាន គឺមិនទាន់គ្រប់គ្រាន់

បណ្ឌិត Nguyen Viet Vinh គឺជាទីប្រឹក្សាជលផល ធ្វើការជាមួយ សម្ព័នភាពជីវិតសត្វសមុទ្រអន្តរជាតិ (International Marinelife Alliance “IMA”) ដែលមានទីតាំងនៅទីក្រុងហាណូយ ។ យើងអាចទាក់ទងតាមរយៈ < nvvinh@marine.org >

## ការប្រើប្រាស់លទ្ធផលពីការវាយតំលៃភាពក្រីក្រដោយមានការចូលរួមនៅខេត្ត Tra Vinh

*Le Quang Binh*

### ការវាយតំលៃដោយមានការចូលរួម (PRA) នៅខេត្ត Tra Vinh

នៅខែមេសា ១៩៩៩ អង្គការអុកហ្វាមអង់គ្លេស ដោយមានដៃគូរជាមួយនិង គណៈកម្មាធិការប្រជាជនខេត្ត Tra Vinh និង ធានាគារពិភពលោក បានធ្វើ ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម(PPA)នៅក្នុងស្រុក២ គឺ Duyen Hai និង Chau Thanh ក្នុងខេត្ត Tra Vinh ។ គោលបំណងនៃការធ្វើ PPA គឺដើម្បីយល់កាន់តែច្បាស់តើអ្នកណាជាប្រជាជនក្រីក្រ តើគេកំណត់ភាពក្រីក្រដូចម្តេច អាទិភាពរបស់គេ តើការផ្លាស់ប្តូរសំខាន់អ្វីខ្លះដែលជះឥទ្ធិពលលើសុខុមាលភាពរបស់ប្រជាជននៅក្នុងខេត្តក្នុងរយៈពេលកន្លងមកនេះ ។ ទិសដៅនៃ PPA គឺៈ

- មានឥទ្ធិពលលើយុទ្ធសាស្ត្រ និង គោលនយោបាយកាត់បន្ថយភាពក្រីក្រ ជាពិសេសលើកម្មវិធីកាត់បន្ថយភាពក្រីក្រ និង ស្រុកឃ្លាន នៅក្នុងខេត្ត Tra Vinh និង តំបន់ផ្សេងទៀតនៃប្រទេសវៀតណាម ។
- លើកកំពស់ការយល់ដឹងរបស់អុកហ្វាមអង់គ្លេសលើភាពក្រីក្រ និង ធ្វើការងារឱ្យកាន់តែហ្មត់ចត់ថែមទៀតលើការវិភាគភាពក្រីក្រនៅខេត្ត Tra Vinh
- លើកកំពស់ការយល់ដឹងក្នុងចំណោមប្រជាជន និង មន្ត្រីនៅខេត្ត Tra Vinh ទាក់ទងនឹងទំហំនៃភាពក្រីក្រ និង យុទ្ធសាស្ត្រផ្សេងៗដើម្បីកាត់បន្ថយភាពក្រីក្រ
- អភិវឌ្ឍន៏គំរោងកាត់បន្ថយភាពក្រីក្រសំរាប់ជនក្រីក្រ និង ក្រុមដែលងាយទទួលរងគ្រោះបំផុតនៅក្នុងខេត្ត Tra Vinh

### លទ្ធផលខ្លះៗ

ក្នុងចំណោមប្រជាជនក្រីក្រនៅក្នុងខេត្ត Tra Vinh ៦ ក្រុមត្រូវបានគេរកឃើញថាក្រីក្របំផុត និង ងាយរងនឹងភាពក្រីក្រៈ

១ ប្រជាជនដែលគ្មានដីធ្លី ដែលពឹងផ្អែកលើការលក់កំលាំងពលកម្ម និង ខ្វះធនធានដែលមានផលិតភាព

២ ប្រជាជនខ្មែរក្រីក្រដែលបញ្ហារួមមាន បញ្ហាភាសា គ្មានដីធ្លី និង មានចំណេះដឹងតិចតួចក្នុងការធ្វើជំនួញ

៣ ស្ត្រីក្រីក្រ ដែលជាមេគ្រួសារ ពឹងផ្អែកលើជំនួយឧបត្ថម្ភពីអ្នកជិតខាង និង បងប្អូន

៤ ប្រជាជននៅដាច់ស្រយាលដែលខ្វះពត៌មាន ដែលជាបញ្ហាចំបងបំផុត

៥ ប្រជាជនមិនចេះអក្សរ ដែលពិបាកនឹងទំនាក់ទំនងជាមួយរដ្ឋាភិបាល (ឧទា. មិនអាចអានពីសៀវភៅណែនាំ និង មិនអាចបំពេញបែបបទសុំឥណទាន) និង

៦ ក្មេងក្រីក្រ ដែលខ្វះខាត ។ គេបានបោះបង់ចោលការសិក្សាដោយសារគ្រួសារមិនអាចបង់ថ្លៃសាលា ឬក៏ធ្វើការដើម្បីរកប្រាក់ចំណូល

មូលហេតុចំបងនៃភាពក្រីក្រដែលបានរកឃើញគឺ ១) មុខរបររកប្រាក់ចំណូលមានតិចតួច ២) គ្មានលទ្ធភាពសន្សំប្រាក់ ៣) គ្មានដីធ្លី ៤) ប្រថុយចិញ្ចឹមបង្គា ។ នៅកន្លែងស្រាវជ្រាវទាំងពីរ លទ្ធភាពរកប្រាក់ចំណូលរបស់ប្រជាជនក្រីក្រគឺខ្វះខាតដោយខ្វះសេវាផ្សព្វផ្សាយកសិកម្ម ។ កសិករក្រីក្រគ្មានលទ្ធភាពចូលរៀនវគ្គបំពាក់បំប៉ន អ្នកចូលរួមជាច្រើនបាននិយាយថា អ្នកគ្រាន់បើ គឺត្រូវបានគេ

ហៅឱ្យចូលរៀន (ស្ត្រីតែងតែមិនត្រូវបានគេរាប់បញ្ចូល)។ លើផ្នែកអប់រំ នៅស្រុក Duyen Hai ស្ទើរតែគ្មានក្មេងនៅក្នុងគ្រួសារក្រីក្រណាម្នាក់ដែលអាចរៀនដល់ថ្នាក់ទី ៩ ឬក៏ទាបជាងមធ្យមសិក្សា និង ស្ទើរតែទាំងអស់មិនបានរៀនដល់ថ្នាក់ទី ៥។

**ការប្រើប្រាស់លទ្ធផល**

នៅថ្នាក់ជាតិ របាយការណ៍ដែលមានចំណងជើងថា "ការវាយតំលៃភាពក្រីក្រដោយមានការចូលរួមនៅខេត្ត Tra Vinh" ត្រូវបានផ្សព្វផ្សាយនៅខែវិច្ឆិកា ១៩៩៩។ វាត្រូវបានគេដាក់ទៅក្នុងរបាយការណ៍មួយ "ប្រទេសវៀតណាម ប្រយុទ្ធនឹងភាពក្រីក្រ" ដែលត្រូវបានផលិតឡើងដោយ ក្រុមការងារភាពក្រីក្រ ជាការសហការគ្នារវាង ភ្នាក់ងាររដ្ឋាភិបាល អ្នកផ្តល់ជំនួយ និង អង្គការក្រៅរដ្ឋាភិបាលធ្វើការដើម្បីលុបបំបាត់ភាពក្រីក្រនៅក្នុងប្រទេសវៀតណាម។ របាយការណ៍នេះត្រូវបានគេប្រើនៅកិច្ចប្រជុំពិគ្រោះយោបល់សំរាប់ប្រទេសវៀតណាមនៅខែ ធ្នូ ១៩៩៩។ បញ្ហាដែលបានលើកឡើងនៅក្នុងរបាយការណ៍គឺ ត្រូវបានគេដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្របង្កើន និង កាត់បន្ថយភាពក្រីក្រ (Comprehensive Poverty Reduction and Growth Strategy CPRGS) សំរាប់ប្រទេសវៀតណាម។ យុទ្ធសាស្ត្របង្កើន និង កាត់បន្ថយភាពក្រីក្រ លើកពី ទិសដៅរួម រចនាសម្ព័ន្ធស្ថាប័ន គោលនយោបាយ និង យុទ្ធសាស្ត្រដំណោះស្រាយ១០ ឆ្នាំ និង ផែនការ ៥ ឆ្នាំ ទៅក្នុងផែនការសកម្មភាពលំអិត។ ជាមួយគ្នានេះ វាត្រូវបានគេប្រើដើម្បីសំរបសំរួលការជួយឧបត្ថម្ភពីអ្នកផ្តល់ជំនួយ អង្គការអន្តរជាតិ និង អង្គការក្រៅរដ្ឋាភិបាលដែលទាក់ទងនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច និង កាត់បន្ថយភាពក្រីក្រ។ វាជាលើកដំបូងហើយនៅក្នុងប្រទេសវៀតណាមដែលភ្ជាប់ការរីកចំរើន និង ភាពក្រីក្រ និង លើកឡើងនូវយុទ្ធសាស្ត្រដើម្បីធ្វើវា។ ជាងនេះទៅទៀត យុទ្ធសាស្ត្របង្កើន និង កាត់បន្ថយភាពក្រីក្រ ក៏ឆ្លុះបញ្ចាំងការឆ្លើយតបរបស់រដ្ឋាភិបាលវៀតណាមលើទិសដៅអភិវឌ្ឍន៍សហសវត្សន៍របស់អង្គការសហប្រជាជាតិ។

នៅថ្នាក់ខេត្ត លទ្ធផលរបស់ PPA ត្រូវបានបង្ហាញជូនដល់គណៈកម្មាធិការប្រជាជមខេត្ត និង មន្ទីរដទៃទៀត។ លទ្ធផលដែលរកឃើញបានជួយដល់អាជ្ញាធរខេត្តមានការយល់ដឹងកាន់តែស៊ីជំរៅថែមទៀតពីភាពក្រីក្រ និង មូលហេតុរបស់វាពីគ្រប់ជ្រុងជ្រោយ-ទស្សនៈវិស័យនៃប្រជាជនក្រីក្រ។ វាត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយដោយនាយកដ្ឋានការងារ សង្គមកិច្ច និង អតីតយុទ្ធជនក្នុងការអភិវឌ្ឍន៍កម្មវិធី ឬគំរោងកាត់បន្ថយភាពក្រីក្រ ជាពិសេស កម្មវិធីកាត់បន្ថយភាពក្រីក្រ និង ស្រេកឃ្លាន។

លទ្ធផលរបស់ PPA ក៏ត្រូវបានប្រើប្រាស់ដោយអង្គការអុកហ្វាមអង់គ្លេស និង ដៃគូររបស់គេ ក្នុងការអភិវឌ្ឍន៍កម្មវិធីកាត់បន្ថយភាពក្រីក្រ។ ឧទាហរណ៍. "ការផ្សព្វផ្សាយកសិកម្មសំរាប់អ្នកក្រ ស្ត្រី និង ជនជាតិភាគតិច" ត្រូវបានអភិវឌ្ឍន៍ដើម្បីបង្កើនបច្ចេកទេសដល់ក្រុមដែលងាយទទួលរងគ្រោះបំផុត គំរោងនេះរួមមាន

- ការអភិវឌ្ឍន៏ក្រុមកសិករនៅថ្នាក់មូលដ្ឋានដោយផ្តោតលើការផ្តល់អំណាចឱ្យប្រជាជន។ នៅពេលដែលប្រជាជនត្រូវបានគេផ្តល់អំណាចឱ្យហើយ ពួកគេអាចទាមទារឱ្យមានសេវាកម្មមានគុណភាព មិនត្រឹមតែផ្នែកផ្សព្វផ្សាយកសិកម្ម ប៉ុណ្ណោះទេ ប៉ុន្តែលើផ្នែកហិរញ្ញវត្ថុ និង ពត៌មានអំពីទីផ្សារ
- ការកសាងសមត្ថភាពសំរាប់ប្រពន្ធ័ផ្សព្វផ្សាយកសិកម្ម ដោយផ្តោតលើវិមជ្ឈការ និង អ្នកផ្តល់សេវាកម្មផ្សេងៗទៀត
- ការសន្ទនាពីគោលនយោបាយនៅថ្នាក់ខេត្ត និង ជាតិ ដើម្បីជួយដល់អ្នកក្រ និង គោលនយោបាយផ្សព្វផ្សាយកសិកម្មមានភាពទន់ភ្លន់តាមយិនឌ័

ដើម្បីជួយដល់កសិករដែលគ្មានដីធ្លី អង្គការអុកហ្វាមអង់គ្លេសបានផ្តល់មូលនិធិដល់សហជីពកសិករវៀតណាមដើម្បីធ្វើការស្រាវជ្រាវលើភាពគ្មានដីធ្លី និង ការងារទំនាក់ទំនងលើបញ្ហាគ្មានដីធ្លី។ បញ្ហានេះបានទាក់ទាញការចាប់អារម្មណ៍ពីរដ្ឋាភិបាល- សហជីព

កសិករត្រូវបានគេអញ្ជើញឱ្យចូលរួមនៅក្នុងក្រុមពិសេសមួយនៃរដ្ឋាភិបាល និង គណៈបក្សកុំមុយនីស្ត ដើម្បីសើរើលើច្បាប់ដីធ្លី និង បញ្ហាគ្មានដីធ្លី ។

អង្គការអុកហ្វាមអង់គ្លេសនឹងបន្តធ្វើការលើបញ្ហានេះ ដោយជួយដល់ខេត្តរកនូវដំណោះស្រាយសមស្របដើម្បីដោះស្រាយបញ្ហាភាពគ្មានដីធ្លីឱ្យមាននិរន្តរភាព និង ពិតប្រាកដ ។ "ការគ្រប់គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាពដើម្បីកាត់បន្ថយភាពក្រីក្រ" ត្រូវបានអភិវឌ្ឍន៍ដើម្បីជួយដល់កសិករដែលគ្មានដីធ្លី និង អ្នកនេសាទធុនតូចឱ្យគ្រប់គ្រងតំបន់ឆ្នេរ និង ទទួលផលប្រយោជន៍ពីការចិញ្ចឹមគ្រុំ ។ គំរោងនេះមានទិសដៅជួយដល់ប្រជាជនមូលដ្ឋាន និង អាជ្ញាធរជាតិឱ្យវិភាជន៍ធនធានដែលមានដល់ប្រជាជនក្រីក្រនៅមូលដ្ឋាន និង ធានាដល់ការប្រើប្រាស់នូវធនធានដែលគេពឹងផ្អែកលើ ។ "លើកកំពស់គុណភាពអប់រំបឋម" មានទិសដៅធានាថាក្មេងក្រីក្រទាំងអស់ មានសិទ្ធិទទួលបាននូវគុណភាពអប់រំជាមូលដ្ឋាន ។ វាត្រូវបានគេបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងទិសដៅផ្លាស់ប្តូរយុទ្ធសាស្រ្តទាំងនេះ

១. អនុញ្ញាតិឱ្យឪពុកម្តាយក្រីក្រមិនបង់ថ្លៃសាលាឱ្យកូនត្រឹមថ្នាក់បឋមសិក្សា
២. ទទួលយកនូវវិធីសាស្រ្ត "ក្មេងជាសំខាន់" ដើម្បីលើកកំពស់លទ្ធផលការរៀនសូត្រ
៣. ផ្តល់ធនធានគ្រប់គ្រាន់ដល់ការអប់រំថ្នាក់បឋមសិក្សា ដោយផ្អែកលើស្តង់ដាជាតិ
៤. ឱ្យគ្រួសារ និង សហគមន៍ចូលរួមនៅក្នុងការសំរេចទាក់ទងនឹងការអប់រំ

## សន្និដ្ឋាន

វាច្បាស់ណាស់ថាលទ្ធផលដែលបានមកពីការស្រាវជ្រាវ និង ការវាយតំលៃអាចត្រូវបានគេយកទៅប្រើដើម្បីគោលដៅផ្សេងៗនៅកំរិតផ្សេងៗ ។ វាអាចគេយកទៅប្រើធ្វើឱ្យមានការផ្លាស់ប្តូរគោលនយោបាយដើម្បីជួយដល់ប្រជាជនក្រីក្រ ស្រ្តី និង ក្រុមជនជាតិភាគតិច ។ វាក៏អាចគេយកទៅប្រើដើម្បីលើកកំពស់ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋានពីមូលហេតុនៃភាពក្រីក្រ និង រៀបចំកម្មវិធីកាត់បន្ថយភាពក្រីក្រកាន់តែប្រសើរសំរាប់ប្រជាជនក្រីក្រ ។ ដំណើរការស្រាវជ្រាវ និង វាយតំលៃក៏អាចបង្កើនការយល់ដឹងរបស់ប្រជាជនក្រីក្រពីមូលហេតុនៃភាពក្រីក្រ និង ដំណោះស្រាយ ។

នៅក្នុងករណីនៃការវាយតំលៃភាពក្រីក្រដោយមានការចូលរួមនៅខេត្ត Tra Vinh អង្គការអុកហ្វាមអង់គ្លេសបានរៀបចំគំរោងផ្សេងៗគ្នា ដើម្បីដោះស្រាយមូលហេតុនៃភាពក្រីក្រ សំរាប់ក្រុមក្រីក្រ និង ងាយទទួលរងគ្រោះ ។ នៅក្នុងគំរោងនិមួយៗមានទាំងការជួយឧបត្ថម្ភដោយផ្ទាល់ ដោយប្រយោល និង ការងារទំនាក់ទំនងដើម្បីផ្លាស់ប្តូរការអនុវត្តន៍ និង គោលនយោបាយ ។ យុទ្ធសាស្រ្តជាច្រើនត្រូវបានគេទទួលយកដើម្បីធានាថា ធនធានត្រូវបានគេប្រើប្រាស់ចំទិសដៅ និង មានប្រសិទ្ធិភាព និង សំណូមពរ ឬ ការស្នើសុំរបស់អ្នកក្រីក្រ និង ក្រុមងាយរងគ្រោះបំផុតត្រូវបានគេដឹង និង ឆ្លើយតប ។

Le Quang Binh គឺជាមន្រ្តីនៃកម្មវិធីអុកហ្វាមអង់គ្លេសប្រចាំខេត្ត Tra Vinh នៃប្រទេសវៀតណាម ។
យើងអាចទាក់ទងតាមរយៈ < LQBinh@oxfam.org.uk > ។

# ពត៌មានពីទស្សនាវដ្ដីរបស់ STREAM

បោះពុម្ពដោយ STREAM- Support to Regional Aquatic Resources Management
Network of Aquaculture Centres in Asia-Pacific (NACA) Secretariat
Suraswadi Building
Department of Fisheries Compound
Kasetsart University Campus
Ladyao, Jatujak, Bangkok 10903
Thailand

ក្រុមអ្នកបោះពុម្ពផ្សាយ

Graham Haylor, នាយកនៃគំរោង STREAM

Le Thanh Luu, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅវៀតណាម

William Savage, អ្នកជំនាញការខាងទំនាក់ទំនងនៃគំរោង STREAM

Sonia Seville, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅហ្វីលីពីន

Thay Somony, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅកម្ពុជា

## គោលបំណង

ទស្សនាវដ្ដីរបស់ STREAMបោះពុម្ពរៀងរាល់ត្រីមាសដើម្បីលើកកំពស់ការចូលរួម, ទំនាក់ទំនង, និង គោលនយោបាយដែលជួយដល់ជីវភាពរស់នៅអ្នកប្រើប្រាស់ធនធានវារិជាតក្រីក្រក្នុងតំបន់អាស៊ីប៉ាស៊ីភិច និង កសាងទំនាក់ទំនងក្នុងវិស័យគ្រប់គ្រងធនធានវារិជាត និង ផ្នែកផ្សេងទៀតនៅក្នុងតំបន់។ ទស្សនាវដ្ដីរបស់ STREAMមានអត្ថបទដែលទាក់ទងនឹងប្រជាជនដែលការចិញ្ចឹមជីវិតរបស់ពួកគេពឹងផ្អែកលើធនធានជលផល ជាពិសេសប្រជាជនដែលមានធនធានតិចតួច អ្នកអនុវត្ត រដ្ឋាភិបាល មិនមែនរដ្ឋាភិបាល និង អន្តរជាតិ ដែលធ្វើការជាមួយពួកគេក្នុងសហគមន៍។ បញ្ហាមានដូចជាៈ ការរៀនសូត្រ, ការគ្រប់គ្រងជំលោះ, បច្ចេកវិទ្យាទំនាក់ទំនង និង ពត៌មាន, ការគ្រប់គ្រងធនធានវារិជាត, ច្បាប់, ការចិញ្ចឹមជីវិត, យិនឌឺ, ការចូលរួម, អ្នកជាប់ពាក់ពន្ធ័, គោលនយោបាយ និង ទំនាក់ទំនង។

គោលបំណងសំខាន់មួយផ្សេងទៀតរបស់ទស្សនាវដ្ដី STREAMគឺផ្ដល់ឱកាសឱ្យបញ្ចេញសំលេងដែលកំរមានដើម្បីឱ្យគេបានលឺ និង មានតំណាងនៅក្នុងវិជ្ជាជីវបោះពុម្ពដែលមានបន្ថិចបន្តួចនៅក្នុងស្ថាប័នរៀនសូត្រ។ មាតិកាក្នុងទស្សនាវដ្ដី មិនត្រូវយកទៅដើម្បីបញ្ជាក់ពីទស្សនៈនៃអង្គការ ឬ ភ្នាក់ងារណាមួយទេ ប៉ុន្តែវាគ្រាន់តែជាគំនិតនៃ

មនុស្សម្នាក់ៗដោយផ្អែកលើបទពិសោធរបស់ពួកគេ។ អ្នកនិពន្ធទទួលខុសត្រូវលើមាតិកាអត្ថបទរបស់ពួកគេ ហើយ STREAMទទួលខុសត្រូវលើភាពលំអៀង និង លើសលួសផ្សេងៗ។

## ការចែកចាយ

ទស្សនាវដ្តីរបស់ STREAMអាចរកបានជា ៣ ទំរង់

- ជាទំរង់អេឡិចត្រូនិចដែលត្រូវបានបោះពុម្ព និង ចែកចាយដោយ មណ្ឌលទំនាក់ទំនង STREAM
- ជាទំរង់ដែលអាចរកបាន ហើយទាញមកពី Website របស់ STREAM គឺ www.streaminitiative.org
- ជាឯកសារបោះពុម្ពដែលចែកចាយដោយ លេខាធិការដ្ឋាននៃ បណ្តាញនៃមជ្ឈមណ្ឌលវារីវប្បកម្ម ក្នុងតំបន់អាស៊ីប៉ាស៊ីភិច

## ការចូលរួមចំណែក

ទស្សនាវដ្តីរបស់ STREAMលើកទឹកចិត្តដល់ការចូលរួមចំណែកជាអត្ថបទដែលទាក់ទងនឹងអ្នកប្រើប្រាស់ធនធាន វារីជាត និង មនុស្សដែលធ្វើការជាមួយពួកគេ។ ទស្សនាវដ្តីរបស់ STREAMkក៏ជួយដល់សហការីដែលធ្វើការនៅថ្នាក់សហគមន៍ដើម្បីឱ្យចងក្រងឯកសារពីបទពិសោធរបស់ពួកគេនៅក្នុងទំព័រទាំងនេះ។

អត្ថបទគួរសរសេរជាភាសាអង់គ្លេសដែលងាយយល់ ហើយមិនឱ្យលើសពី ១000 ពាក្យ ( ប្រហែល ២ ទំព័រ A4)

អ្នកអាចផ្តល់ជាអត្ថបទផ្សេងៗទៅឱ្យលោក William Savage អ្នកបោះពុម្ពផ្សាយ ទស្សនាវដ្តីរបស់ STREAMតាមរយៈ savage@loxinfo.co.th.

ពត៌មានបន្ថែមសូមទាក់ទងលោក Graham Haylor នាយកនៃគំរោង STREAM តាមរយៈអ៊ីមែល ghalor@loxinfo.co.th

## ពត៌មានពី STREAM

STREAM (ជួយគាំទ្រការគ្រប់គ្រងធនធានវារីជាតក្នុងតំបន់ )ជាគំរោងមួយដែលគ្រោងឡើងក្នុងរយៈ ពេល៥ឆ្នាំនៃកម្មវិធីការងាររបស់ NACA (បណ្តាញនៃមជ្ឈមណ្ឌល វារីវប្បកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច) ។ គំរោងមានទិសដៅជួយដល់ទីភ្នាក់ងារ និងស្ថាប័នផ្សេង១ឱ្យៈ

- ប្រើប្រាស់ពត៌មានដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធិភាព
- យល់ឱ្យកាន់តែច្បាស់ថែមទៀតពីជីវភាពរបស់ប្រជាជនក្រីក្រ និង
- អាចឱ្យប្រជាជន ក្រីក្រ ប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនលើគោលនយោបាយ និង ដំណើរការដែលជះឥទ្ធិពលលើជីវិតរបស់ពួកគេ ។

គំរោង នឹងធ្វើការងារនេះតាមរយៈការជួយអភិវឌ្ឍន៍គោលនយោបាយ និង ដំណើរការសំរបសំរួលស្ថាប័ន និងការកសាងសមត្ថភាពដើម្បីៈ

- រកឱ្យឃើញនូវបញ្ហានៃការគ្រប់គ្រងធនធានវារីជាតដែលជះឥទ្ធិពលទៅលើជីវភាពអ្នកក្រីក្រ
- ពិនិត្យ និង វាយតំលៃលើយុទ្ធវិធីគ្រប់គ្រងផ្សេង១គ្នា
- ផ្សព្វផ្សាយពត៌មាន
- ធ្វើបណ្តាញនៅក្នុង/រវាងវិស័យ និងរវាងប្រទេស

គំរោងគឺផ្អែកលើភាពជាដៃគូរដែលជាប់ទាក់ទងចាប់តាំងពីការករកើតនូវការរួបរួមជាដៃគូរ (DFID, VSO, FAO) ដែលជួយដល់ (NACA) ។ គំរោងនឹងទទួលយកនូវយុទ្ធវិធីសមស្របមួយដើម្បីសំរេចឱ្យបាននូវ ទំនាក់ទំនងរវាងអ្នកជាប់ពាកលពន្ធ័ទាំងអស់ដែលជាប់ទាក់ទិននិងការគ្រប់គ្រងធនធានវារីជាត និងជួយពួកគេឱ្យរួម ចំណែកក្នុងការរៀបចំ, អនុវត្តន៍ និងការគ្រប់គ្រងគំរោង ។

ការធ្វើការងាររបស់ដៃគូរត្រូវបានសំរបសំរួល នៅក្នុងប្រទេសនិមួយ១តាមរយៈក្រុមសំរបសំរួលជាតិ ដែលរួមមានៈ អ្នកសំរបសំរួលជាតិ (មន្ត្រីជាន់ខ្ពស់ដោយមានការយល់ព្រមជាមួយរដ្ឋាភិបាល) និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនង (ជាមន្ត្រីដែលធ្វើការពេញម៉ោងហើយជួយឧបត្ថម្ភក្នុងរយៈពេល២ ឆ្នាំដំបូងដោយ STREAM) ហើយភ្ជាប់ទំនាក់ទំនងជាមួយអ្នកជាប់ពាក់ពន្ធ័ផ្សេង១ ។ អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនងត្រូវបានគេផ្តល់ឱ្យនូវ Hardware( មានដូចជា កុំព្យូទ័រ ម៉ាស៊ីនស្កេន...), Software (កម្មវិធីកុំព្យូទ័រ ដូចជា word, excel..), បំពាក់បំប៉ន, ការជួយឧបត្ថម្ភដល់បច្ចេកវិទ្យាពត៌មាន បណ្តាញ និង ធនធានមនុស្ស ហើយភ្ជាប់ជាមួយនឹងអ្នកជាប់ពាក់ពន្ធ័តាមរយៈ Internet ។

ការសំរបសំរួលជាតិគឺអនុវត្តទៅតាម អត្ថបទយុទ្ធសាស្ត្រនៃប្រទេស(CSP) ដោយមានការពិនិត្យឡើងវិញជារៀង រាល់ឆ្នាំ ហើយធ្វើឡើងដោយអ្នកសំរបសំរួល និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនង ដោយមានការពិគ្រោះយោបល់ ជាមួយអ្នកជាប់ពាក់ពន្ធ័។ CSP រកឱ្យឃើញនូវបញ្ហា, ផ្តោតលើទំនាក់ទំនងក្នុងតំបន់, ធ្វើសំណើរ និង ធ្វើអាទិភាព សកម្មភាពសំខាន់ និង ស្វែងរកថវិកាសំរាប់អនុវត្តសកម្មភាពនេះពី STREAM និងពីកន្លែងផ្សេងៗទៀត (ដោយមាន ការជួយជ្រោមជ្រែងពី STREAM )។

កាិរយាល័យតំបន់របស់ STREAM (នៅលេខាធិការ NACA ទីក្រុងបាងកក)ដឹកនាំគំរោង, ផ្តល់នូវតួនាទី សំរបសំរួលក្នុងតំបន់, និង មូលនិធិ និង គ្រប់គ្រងបញ្ហាដែលទាក់ទងនឹង ការចិញ្ចឹមជីវិត, ការអភិវឌ្ឍន៏គោលនយោ បាយ ទំនាក់ទំនង និង បញ្ហាពិសេសផ្សេងៗទៀត។

ការប្រតិបត្តិរបស់ STREAM គឺជាដំណើរការដដែលៗមួយដែលធ្វើសាកល្បង នៅឆ្នាំទីមួយនៅកម្ពុជា និង វៀតណាមដែលជាកន្លែងមានឳកាសដើម្បីដោះស្រាយនូវភាពក្រីក្រ និងលើកកំពស់អភិបាលកិច្ចល្អ STREAM មានគំរោងពង្រីកទៅបណ្តាប្រទេសផ្សេងៗទៀតនៅពេលទទួលបានបទពិសោធន៏, មេរៀនត្រូវ បានរៀន, ការជះឥទ្ធិពលត្រូវបានដឹង, ហើយថវិកាបន្ថែមត្រូវបានធានា ។ យុទ្ធសាស្ត្រទំនាក់ទំនងរបស់ STREAM គឺមាន ទិសដៅជួយបង្កើនឥទ្ធិពលដោយធានាថាចំណេះដឹងដែលមានស្រាប់នៅក្នុងតំបន់ និង ជំនាញការ បានជា ពតិមានដល់ ដំណើរការផ្លាស់ប្តូរនៅក្នុងតំបន់ ហើយបទពិសោធត្រូវបានចែកចាយទូទាំងតំបន់អាស៊ីប៉ាស៊ីភិច។ ទស្សនាវដ្តីរបស់ STREAM រួមជាមួយវេទិកាពិភាក្សាដែលមាននៅលើ Website គឺជាផ្នែកនៃយុទ្ធសាស្ត្រនេះ។

អាស័យដ្ឋានទំនាក់ទំនង:

STREAM National Communications Hub Managers

| | |
|---|---|
| Cambodia | : Sem Viryak, < cfdo@camnet.com.kh > |
| Philippines | : Elizabeth Gonzales < streambfar-phil@skyinet.net > |
| Nepal | : Nilkanth Pokhrel < agroinfo@wlink.com.np > |
| Vietnam | : Nguyen Song Ha < nguyensongha@fpt.vn > |